**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសហគមន៍អាជីវកម្មធុនតូច

## «សិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបងចាប់ផ្តើមពីឆ្នាំ២០១៦-២០២១»

ស្រាវជ្រាវពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **ក. សាឡឿន សំប៉ូង**

**ក. អេម សុនីតា**

សាស្ត្រាចារ្យណែនាំៈ

**បណ្ឌិតៈ ឌឹត សំណាង**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសហគមន៍អាជីវកម្មធុនតូច

## «សិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបងចាប់ផ្ដើមពីឆ្នាំ២០១៦-២០២១»

ស្រាវជ្រាវពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ**ក. សាឡឿន សំប៉ង**
**ក. អោម សុនីតា**

សាស្ត្រាចារ្យណែនាំៈ
**បណ្ឌិតៈ ឌឹត សំណាង**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ**សារឿន សំប៉ុខ** និង**អោម សូនីតា** ជានិស្សិតផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

យើងខ្ញុំទាំងពីរ សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **អ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើត និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅដល់កូនប្រកបដោយព្រហ្មវិហារធម៌ និងបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដើម្បីផ្តល់លទ្ធភាពឲ្យយើងខ្ញុំទាំងពីរបានរៀនសូត្ររហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញផ្នែករដ្ឋបាលសាធារណៈជំនាន់ទី ១៤នេះ។

យើងខ្ញុំទាំងពីរ សូមធ្វើការថ្លែងអំណរគុណក្រៃលែងចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** ដែលបានផ្តល់ឱកាសដល់រូបយើងខ្ញុំទាំងពីរមានលទ្ធភាពក្នុងការសិក្សាផ្នែករដ្ឋបាលសាធារណៈនៅក្នុង សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាពិសេសបានអនុញ្ញាតដល់រូបយើងខ្ញុំទាំងពីរអាចចូលរួមសរសេរសារណានៅក្នុងឆ្នាំនេះ។

ហើយយើងខ្ញុំទាំងពីររូប ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ សាស្រ្តាចារ្យ **ឌឹត សំណាង** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំអំពីរបៀបសរសេរ ខិតខំពន្យល់ជាច្រើននូវប្រធានបទខាងលើ ថែមទាំងចែករំលែកបទពិសោធន៍ល្អៗ និងតែងតែជម្រុញលើកទឹកចិត្តដល់យើងខ្ញុំទាំងពីរឲ្យសរសេរសារណាមួយនេះទទួលបានជោគជ័យ។

បន្ទាប់មកទៀតយើងខ្ញុំទាំងពីរក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅ ដល់ប្រធានអង្គការOsmose (អូស្មូស) និងប្រធានសហគមន៍សារាយទន្លេដែលបានជួយណែនាំ និងផ្តល់ជាព័ត៌មានដែលមានអត្ថប្រយោជន៍ជាច្រើនដល់រូបយើងខ្ញុំទាំងពីរដើម្បីសម្រេចជោគជ័យក្នុងការសរសេរសារណាមួយនេះ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីររូបសូមគោរពជូនពរចំពោះសាស្រ្តាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចឲ្យមានសុខភាពល្អព្រមទាំងទទួលបានជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

ជាបឋមយើងខ្ញុំទាំងពីរពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលទទួលបានឱកាសចូលមកសិក្សាក្នុងសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលជាសាកលវិទ្យាល័យមួយមានភាពល្បីល្បាញខាងផ្នែកច្បាប់ក៏ដូចជាផ្នែករដ្ឋបាលសាធារណៈផងដែរ។ បន្ថែមពីនេះទៅទៀតគ្រប់និស្សិតទាំងអស់សុទ្ធតែទទួលបានការអប់រំ និងការបង្រៀនពីលោកគ្រូ អ្នកគ្រូ សាស្រ្តចារ្យដែលមានជំនាញ និងបទពិសោធន៍មកជាច្រើនឆ្នាំ។

ស្របគ្នានេះដែរយើងខ្ញុំទាំងពីរគឺជានិស្សិតផ្នែករដ្ឋបាលសាធារណៈ ដោយសារតែឆ្នាំនេះជាឆ្នាំដែលត្រូវបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ ដូច្នេះហើយទើបយើងខ្ញុំទាំងពីរនាក់សម្រេចជ្រើសរើសយកប្រធានស្តីពី **ការគ្រប់គ្រងសហគមន៍អាជីវកម្មធុនតូច«សិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបងចាប់ផ្តើមពីឆ្នាំ២០១៦-២០២១»** មូលហេតុដែលយើងខ្ញុំទាំងពីរសម្រេចចិត្តក្នុងការជ្រើសរើសប្រធានបទនេះ ក៏ព្រោះតែពួកយើងមានបំណងក្នុងការសិក្សាស្វែងយល់អំពីការប្រព្រឹត្តិទៅរបស់អាជីវកម្មសហគមន៍ ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ និងដើម្បីចូលរួមលើកស្ទួយដល់ផលិតផលកែច្នៃពីកំប្លោកដែលជាស្នាដៃរបស់បងប្អូនសិប្បករយើង។ យ៉ាងណាមិញដោយសារពេលវេលារួមទាំងចំណេះដឹងជាមូលដ្ឋាននៅមានកម្រិតផងដែរនោះ ដូច្នេះការស្រាវជ្រាវមួយនេះនឹងអាចមានការខ្វះខាត ពាក្យពេចន៍ ឃ្លាឃ្លោងត្រង់ចំណុចណាមួយចំនួន ដូចនេះសូមសាស្រ្តាចារ្យ និស្សិត និងមិត្តអ្នកអានទាំងអស់មេត្តាខន្តី អភ័យទោសដល់យើងខ្ញុំដែលជាអ្នកស្រាវជ្រាវផង។

ជាចុងក្រោយយើងខ្ញុំទាំងពីរមានសេចក្តីរីករាយនិងទទួលស្វាគមន៍រាល់ការរិះគន់ក្នុងន័យស្ថាបនា និងគំនិតទាំងឡាយពីសំណាក់សាស្រ្តាចារ្យ និស្សិត និងមិត្តអ្នកអានទាំងអស់គ្នាដើម្បីជាការអភិវឌ្ឍន៍ក្នុងការស្រាវជ្រាវប្រធានបទមួយឲ្យកាន់តែល្អប្រសើរដល់អ្នកដែលមានបំណងក្នុងការយកទៅសិក្សាបន្ត។

# មាតិកា


បញ្ជីអក្សរកាត់.....iv
សេចក្តីផ្តើម.....១
១. លំនាំបញ្ហា.....១
២. ចំណោទបញ្ហា.....២
៣. គោលបំណងនៃការស្រាវជ្រាវ.....២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ.....៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ.....៣
៥.១. វិធីសាស្ត្រនៃការវិភាគទិន្នន័យ.....៣
៥.២. ប្រភេទ និងប្រភពទិន្នន័យ.....៣
៥.៣. ការជ្រើសរើសគម្រូសំណាក.....៤
៥.៤. ទីកន្លែងសម្ភាសន៍ និង ការផ្តល់ចម្លើយ.....៤
៥.៥. អ្នកផ្តល់ចម្លើយ.....៤
៦. សារៈសំខាន់នៃការស្រាវជ្រាវ.....៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៤


## ជំពូកទី១
## សញ្ញាណនៃការគ្រប់គ្រងអាជីវកម្មខ្នាតតូច


១.១. សញ្ញាណនៃការគ្រប់គ្រងអាជីវកម្មខ្នាតតូច.....៦
១.២. និយមន័យនៃពាក្យការគ្រប់គ្រងអាជីវកម្មខ្នាតតូច.....១៣
១.៣. ចរិកលក្ខណៈនៃអាជីវកម្មខ្នាតតូច.....១៥
១.៤. តួនាទីរបស់ស្ថាប័នរដ្ឋក្នុងការជួយអាជីវកម្មខ្នាតតូច.....១៥
១.៤.១. គោលនយោបាយ និងកាលានុវត្តភាពនៃសហគ្រាសខ្នាតតូច និងមធ្យម.....១៥
១.៤.២. ការលើកទឹកចិត្តផ្នែកគយ សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម.....១៧
១.៤.៣. ដំណោះស្រាយរបស់រដ្ឋសម្រាប់បញ្ហាប្រឈមរបស់សហគ្រាសខ្នាតតូច និងមធ្យម.....២០
១.៥. អត្ថប្រយោជន៍នៃអាជីវកម្មខ្នាតតូច.....២១
១.៥.១. ការបង្កើតការងារ និងកាត់បន្ថយនិកម្មភាពសម្រាប់កម្ពុជា.....២២

១.៥.២. ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់គុណភាពរស់នៅ ....................................២២

**ជំពូកទី២**

**ទស្សនទានទូទៅស្តីពីការគ្រប់គ្រងអាជីវកម្មខ្នាតតូច«សិប្បកម្មកែច្នៃកំប្លោក»**

**២.១. ឈ្មោះ ទីតាំង និងភូមិសាស្ត្រនៃតំបន់សិក្សា**...................................................... ២៣
២.១.១. ឈ្មោះនៃ ខេត្តបាត់ដំបង................................................................................ ២៣
២.១.២. ទីតាំង និងភូមិសាស្ត្រនៃខេត្តបាត់ដំបង .............................................................. ២៣
**២.២. ប្រវត្តិនៃសិប្បកម្មកំប្លោកសហគមន៍សារាយទន្លេ**...........................................................២៥
**២.៣. រចនាសម្ព័ន្ធនៃសហគមន៍សិប្បកម្មកែច្នៃកំប្លោកសារាយទន្លេ** ..........................................២៦
២.៣.១. រចនាសម្ព័ន្ធនៃសហគមន៍សិប្បកម្មកែច្នៃកំប្លោក...........................................................២៦
២.៣.២. ការចូលរួមរបស់ស្ត្រីក្នុងការងារសហគមន៍....................................................................២៦
**២.៤. តួនាទីរបស់ប្រធាន អនុប្រធាននៃសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ**
២.៤.១. តួនាទីរបស់ប្រធានសិប្បកម្មកំប្លោក ...................................................................... ២៧
២.១.២. តួនាទីរបស់អនុប្រធានសិប្បកម្មកំប្លោក ...................................................................២៨
២.១.៣. ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង ...........................................................................២៨
**២.៥. វិន័យការងារចំពោះសមាជិកក្នុងសហគមន៍សិប្បកម្មកែច្នៃកំប្លោក**.................................២៩
**២.៦. ដំណើរការការងារនៃសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ** ................................៣០
២.៦.១. ដំណើរការការងារមុនពេលមានការរីករាលត្បាតនៃជំងឺកូវីដ១៩................................... ៣២
២.៦.២. ដំណើរការការងារអំឡុងពេលមានការរីករាលត្បាតនៃជំងឺកូវីដ១៩................................ ៣២
**២.៧. ការគ្រប់គ្រងហិរញ្ញវត្ថុក្នុងសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ**...... ៣៣
២.៧.១. សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ........................................................................ ៣៣
២.៧.២.. ផែនការថវិកា ....................................................................................................... ៣៣

**ជំពូកទី៣**

**លទ្ធផលនៃការវិភាគសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ**

**៣.១. ស្ថានភាពទូទៅរបស់សិប្បករ**.......................................................................................៣៦
៣.១.១. ឆ្នាំនៃការចាប់ផ្តើមធ្វើការក្នុងសហគមន៍..........................................................................៣៦
៣.១.២. គុណសម្បត្តិ និងគុណវិបត្តនៃការធ្វើការក្នុងសហគមន៍ ................................................ ៣៧
**៣.២. បញ្ហាប្រឈម**........................................................................................................... ៣៧

៣.២.១. សហគមន៍.................................................................................................... ៣៧
៣.២.២. សិប្បករ .................................................................................................... ៣៨
**៣.៣. ដំណោះស្រាយ** .................................................................................................... ៣៩
**៣.៤. ទិសដៅអនាគត** .................................................................................................... ៣៩
**សេចក្ដីសន្និដ្ឋាន**
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| ល.រ | អក្សរកាត់ | ពាក្យពេញជាភាសាអង់គ្លេស | ពាក្យពេញជាភាសាខ្មែរ |
|---|---|---|---|
| ១ | GDP | Gross Domestic Product | ផលិតផលជាតិសរុប |
| ២ | MSME | Micro Small and Medium Enterprise | សហគ្រាសខ្នាតតូចនិងមធ្យម |
| ៣ | NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| ៤ | SME | Small and medium-sized enterprises | សហគ្រាសខ្នាតតូចនិងមធ្យម |

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ជាការពិតណាស់ ប្រទេសកម្ពុជាបន្ទាប់ពីឆ្លងកាត់របបសង្គ្រាមកម្ពុជាប្រជាធិបតេយ្យ រួចមកធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសមានការធ្លាក់ចុះដល់ចំណុចសូន្យ។ ម្យ៉ាងវិញទៀតស្ទើតែពោល់សកម្មភាពនៃគម្រោងអភិវឌ្ឍន៍ទាំងអស់ត្រូវបានលុបបំបាត់ចោលទាំងស្រុង និងមានតិចតួចបំផុតទៅតាមតំបន់អភិវឌ្ឍន៍នោះ។ ក៏ព្រោះតែផ្នត់គំនិតរបស់ប្រជាជននាសម័យនោះច្រើនតែផ្តោតទៅលើការប្រកបរបរកសិកម្មដូចជា ធ្វើស្រែចម្ការ ចិញ្ចឹមសត្វ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃទៅតាមលក្ខណៈគ្រួសារនីមួយៗ ជាជាងការធ្វើអាជីកម្មជាសហគមន៍។

ផ្ទុយទៅវិញចាប់តាំងពីឆ្នាំ២០០០មក នៅទូទាំងប្រទេសកម្ពុជាមានក្រុមប្រជាពលរដ្ឋជាច្រើនបានសម្តែងនៅការចាប់អារម្មណ៍ និងឆន្ទៈយ៉ាងមោះមុតក្នុងការចូលរួមរៀបចំប្រកបរបរជាសហគមន៍ដើម្បីធ្វើការទាក់ទងគ្នាទៅវិញទៅមក និងចែករំលែកនូវភាពខ្វះខាតមួយចំនួនដើម្បីបំពេញតម្រូវការជាទូទៅនៅក្នុងភូមិ ឃុំរបស់ខ្លួន។

ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជាក៏កំពុងខិតខំ ប្រឹងប្រែងរកមធ្យោបាយដើម្បីអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃព្រមទាំងជម្រុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋនៅតាមទីជនបទ និងសហគមន៍ឲ្យងាកមកចាប់អារម្មណ៍ និងចូលរួមក្នុងការប្រកបរបរបែបអាជីវកម្មសហគមន៍វិញ ដើម្បីជួយជម្រុញដល់កម្រិតជីវភាពរស់នៅ និង បង្កើននូវអត្រាប្រាក់ចំណូលរបស់ប្រជាពលរដ្ឋឲ្យខ្ពស់ផុតពីបន្ទាត់នៃភាពក្រីក្រ។ ជាពិសេសក្នុងតំបន់ណាដែលកំពុងប្រឈមមុខនឹងភាពក្រីក្រ និងអត្រាប្រាក់ចំណូលរបស់ប្រជាជនក្នុងតំបន់នោះទទួលបានកម្រិតទាប ដែលជាហេតុធ្វើឲ្យមានការទាមទារក្នុងការបង្កើនមនសិការ និងភាពជាអ្នកដឹកនាំក្នុងការអភិវឌ្ឍន៍សហគមន៍ឲ្យជឿនលឿនតាមដែលអាចធ្វើទៅបាន។ តែការអភិវឌ្ឍន៍នេះត្រូវរៀបចំទិសដៅឲ្យបានច្បាស់លាស់ទើបធ្វើឲ្យកំណើនសេដ្ឋកិច្ចមានការកើនឡើងដូចដែលយើងបានរំពឹងទុក។ ដូចនេះការអភិវឌ្ឍន៍សហគមន៍ គឺត្រូវតែមានការចូលរួមពីប្រជាជនសាមញ្ញឡើងទៅ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនក្នុងការជម្នះរាល់ឧបសគ្គទាំងឡាយដែលរួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ វិស័យទំនាក់ទំនងផ្សេងៗ ដើម្បីធ្វើឲ្យមានកំណើនជីវភាពរស់នៅរបស់ប្រជាជន។ ទន្ទឹមនឹងនេះការចូលរួមពីប្រជាពលរដ្ឋពិតជាជាប់ទាក់ទងជាមួយ នឹងគោលដៅអភិវឌ្ឍន៍របស់រដ្ឋាភិបាលក្នុងការសម្រេចចិត្តនូវរាល់សកម្មភាពក្នុងការកំណត់អាទិភាពការផ្តួចផ្តើមគំនិត អនុវត្តន៍សកម្មភាពជាដៃគូរ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ក៏ដូចជាការរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយរាល់បញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍សហគមន៍។ ហេតុនេះហើយក្នុងនាមយើងខ្ញុំទាំងពីរជានិស្សិតផ្នែករដ្ឋបាលសាធារណៈ ពិតជាចង់ឃើញសេដ្ឋកិច្ចរបស់ប្រជាជនដែលរស់នៅតាមទីជនបទនិងសហគមន៍នានានៅក្នុងប្រទេសកម្ពុជាមានកម្រិតជីវភាពល្អប្រសើរ និងមិនមានការជួបប្រទះផលលំបាកនាពេលអនាគត។ ដូចនេះយើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទ ការគ្រប់គ្រងសហគមន៍អាជីវកម្មធុនតូច “សិប្បកម្មកែច្នៃ

កំប្លោកខេត្តបាត់ដំបងចាប់ពីឆ្នាំ២០១៦-២០២១» ដែលមានទីតាំងស្ថិតនៅក្នុងភូមិព្រៃកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង យកមកសិក្សា។

## ២. ចំណោទបញ្ហា

តាមរយៈការបកស្រាយខាងលើរួចមក យើងសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងតែខិតខំប្រឹងប្រែងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើដំណើរការនៃការប្រព្រឹត្តទៅរបស់អាជីវកម្មសហគមន៍ និងបង្កើតឱកាសឲ្យមានការចូលរួមជាសកម្មភាព ដើម្បីរិះរកគ្រប់មធ្យោបាយយកមកដោះស្រាយរាល់បញ្ហាដែលកើតមានឡើងនៅក្នុងសហគមន៍ (សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌)។ ដូច្នេះហើយនាំឲ្យរូបយើងខ្ញុំទាំងពីរនាក់បានចោទសួរជាសំណួរដូចតទៅ ៖

- តើប្រជាជនក្នុងសហគមន៍ប្រកបមុខរបរអ្វី?
- តើបញ្ហាអ្វីខ្លះដែលជាបញ្ហាចម្បងក្នុងសហគមន៍អាជីវកម្ម?
- តើគម្រោង ឬផែនការនិងការអនុវត្តក្នុងសហគមន៍អាជីវកម្មមានដំណើរការយ៉ាងដូចម្ដេច?
- តើអាជីវកម្មសហគមន៍ធុនតូច ឬ មធ្យម បានចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចជាតិដូចម្ដេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទ ការគ្រប់គ្រងសហគមន៍អាជីកម្មធុនតូច«សិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបងចាប់ពីឆ្នាំ២០១៦-២០២១» នេះគឺយើងខ្ញុំទាំងពីរនាក់ចង់ស្វែងរកបទពិសោធន៍ថ្មីៗក្នុងការដឹកនាំសហគមន៍អាជីកម្ម និងបង្កើតចំណេះដឹងបន្ថែមទៅលើការគ្រប់គ្រងសហគមន៍អាជីវកម្ម និងដំណើរការចុះបញ្ជីរបស់សិប្បកម្មនីមួយៗ។ ដូច្នេះហើយដើម្បីសម្រេចបាននូវការស្រាវជ្រាវនេះ គឺត្រូវមានគោលបំណងដូចខាងក្រោម ៖

- សិក្សាអំពីស្ថានភាពទូទៅរបស់សិប្បករ និងប្រជាជនក្នុងនៅសហគមន៍
- សិក្សាអំពីផែនការទីផ្សារ និងរចនាសម្ព័ន្ធរបស់សហគមន៍សារាយទន្លេ
- សិក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយនានានៅក្នុងសហគមន៍សារាយទន្លេ និងផ្តល់អនុសាសន៍ចំពោះការស្រាវជ្រាវ
- សិក្សាអំពីឥទ្ធិពលនៃអាជីវកម្មធុនតូចលើកំណើនសេដ្ឋកិច្ចជាតិ
- សិក្សាអំពីយន្តការរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទៅលើអាជីវកម្មសហគមន៍។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សានេះយើងខ្ញុំបានជ្រើសរើសយកនូវសិប្បកម្មមួយ ដែលស្ថិតនៅក្នុងតំបន់ព្រៃកទាល់ដែលមានឈ្មោះថា សិប្បកម្មកែច្នៃកំប្លោកសារាយទន្លេ ដែលមានទីតាំងស្ថិតនៅភូមិព្រៃកទាល់ ឃុំកោះជីវាំង ស្រុក

ឯកភ្នំ ខេត្តបាត់ដំបង។ ការសិក្សានេះមានដែនកំណត់រយៈពេល៦ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំ២០១៦ដល់២០២១ ព្រោះខាងសហគមន៍ក្តោបក្តាបទិន្នន័យបានច្បាស់លាស់ និងខាងសហគមន៍ទទួលបានប្រជាប្រិយភាពខ្លាំងក្នុងរយៈពេល៦ឆ្នាំនេះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៥.១. វិធីសាស្ត្រនៃការវិភាគទិន្នន័យ

វិធីសាស្ត្រនៃការចាប់យកគម្រូសំណាក គឺយោងទៅលើវិធីសាស្ត្រគម្រូសំណាកមិនចៃដន្យ ជាវិធីសាស្ត្រមួយដែលគេនិយមយកមកប្រើសម្រាប់លក្ខខណ្ឌចាំបាច់សមរម្យតាមគោលបំណងតាមការវិនិច្ឆ័យ និងសមត្ថភាពរបស់អ្នកសិក្សា។ វិធីសាស្ត្រចាប់យកគម្រូសំណាកមិនចៃដន្យអនុញ្ញាតឲ្យអ្នកសិក្សាជ្រើសរើសគម្រូសំណាកតិច សមល្មមនឹងលទ្ធភាព ពេលវេលាខ្លី មានភាពបត់បែនជាងវិធីសាស្ត្រចៃដន្យ ហើយលទ្ធផលនៃការសិក្សាអាចមានភាពជឿជាក់ និងអាចទទួលយកបាន។

### ៥.២. ប្រភេទ និងប្រភពទិន្នន័យ

ប្រភេទទិន្នន័យដែលនឹងលើកយកមកធ្វើជាអំណះអំណាងក្នុងការសិក្សាស្រាវជ្រាវនេះគឺជាទិន្នន័យដែលមានស្រាប់ Secondary Data (ទិន្នន័យទីពីរ) និងទិន្នន័យអង្កេត ឬទិន្នន័យចម្បង Primary Data (ទិន្នន័យទីមួយ) ដើម្បីឲ្យការស្រាវជ្រាវនេះមានលក្ខណៈជាការសិក្សាបែបវិភាគស៊ីជម្រៅ មានបទដ្ឋានបច្ចេកទេសច្បាស់លាស់ និងមានទម្រង់លក្ខណៈវិទ្យាសាស្ត្រ។

ប្រភេទទិន្នន័យដែលមានស្រាប់ គឺជាទិន្នន័យដែលប្រមូលបានមកពីសៀវភៅ និក្ខេបបទនិស្សិតរៀមច្បងជំនាន់មុនៗដែលមាននៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រឹត្តិប័ត្រព័ត៌មាន អត្ថបទស្រាវជ្រាវ ការសែត ទស្សនាវដ្តី កម្រងឯកសារដែលចេញផ្សាយដោយក្រសួងអប់រំ និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងរបាយការណ៍នានាមួយចំនួនដែលពាក់ព័ន្ធនឹងសារណានេះ។

ប្រភពទិន្នន័យអង្កេត ឬទិន្នន័យចម្បង ទទួលបានពីការផ្តល់ចម្លើយពីអ្នកឆ្លើយតាមការសម្ភាសន៍ផ្ទាល់តាមទូរស័ព្ទមួយទល់នឹងមួយ ជាមួយបុគ្គលិក និងសមាជិកនានាដែលកំពុងបំពេញការងារនៅក្នុងសិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបង ដែលមានទីតាំងស្ថិតនៅក្នុងភូមិព្រែកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

### ៥.៣. ការជ្រើសរើសគម្រូសំណាក

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះកំណត់ចំនួនគម្រូសំណាកតាមលក្ខណៈសមរម្យ (Convenience Sampling) ដោយសារៈ

- មានភាពសាមញ្ញក្នុងការប្រមូលទិន្នន័យ
- កាត់បន្ថយការចំណាយ និងចំណេញពេលវេលា

- អ្នកចូលរួមផ្តល់ចម្លើយដែលជ្រើសរើសទាំងអស់នោះ នឹងអាចជាតំណាងឲ្យចម្លើយរួមទូទៅក្នុងកម្រិតជឿជាក់មួយបានសម្រាប់យកទៅធ្វើការសន្និដ្ឋានពីព្រោះអ្នក ផ្តល់ចម្លើយដែលបានជ្រើសរើសនោះ សុទ្ធសឹងជាអ្នកពាក់ព័ន្ធទៅនឹងការងារនៅក្នុងសិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបងស្រាប់។

### ៥.៤. ទីកន្លែងសម្ភាសន៍ និង ការផ្តល់ចម្លើយ

សិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបង ដែលមានទីតាំងស្ថិតនៅក្នុងភូមិព្រែកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

### ៥.៥. អ្នកផ្តល់ចម្លើយ

- ថ្នាក់ដឹកនាំសិប្បកម្មកែច្នៃកំប្លោក ចំនួន ២នាក់
- បុគ្គលិក និងសមាជិកកំពុងបំពេញការងារនៅក្នុងសិប្បកម្មកែច្នៃកំប្លោក ចំនួន១៤នាក់
- ចំនួនសរុបនៃអ្នកឆ្លើយតបសម្ភាសន៍១៤នាក់

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវចំពោះប្រធានបទខាងលើមានដូចតទៅៈ

- យល់ពីទ្រឹស្តីនៃសហគមន៍ និងទ្រឹស្តីមួយចំនួនទៀតដែលផ្សារភ្ជាប់ទៅ និងការអភិវឌ្ឍន៍សហគមន៍
- យល់ដឹងពីភាពខុសគ្នារវាងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង
- យល់ដឹងពីតួនាទីរបស់សហគមន៍អាជីវកម្ម
- យល់ដឹងពីសារៈសំខាន់នៃការធ្វើអាជីវកម្មសហគមន៍
- កំណត់រកចំណុចខ្សោយ និងរកវិធានក្នុងការដោះស្រាយ
- ផ្តល់ជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវបែបសារណានេះក្រុមយើងខ្ញុំបានបែងចែកជា៣ជំពូកដែលពុំរាប់បញ្ចូលសេចក្តីផ្តើម សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ឡើយ។ចំណងជើងជំពូកទាំងបីរួមមានៈ

- ជំពូកទី១ៈ សញ្ញាណនៃការគ្រប់គ្រងអាជីវកម្មធុនតូច
- ជំពូកទី២ៈ ទស្សនទានទូទៅស្តីពីការគ្រប់គ្រងអាជីវកម្មធុនតូច«សិប្បកម្មកែច្នៃកំប្លោក»
- ជំពូកទី៣ៈ លទ្ធផលនៃការវិភាគសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ

# ជំពូកទី១
# សញ្ញាណនៃការគ្រប់គ្រងអាជីវកម្មធុនតូច

# ជំពូកទី១

# សញ្ញាណនៃការគ្រប់គ្រងអាជីវកម្មធុនតូច

## ១.១. សញ្ញាណនៃការគ្រប់គ្រងអាជីវកម្មធុនតូច

សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានគេចាត់ទុកថាជាកម្លាំងជម្រុញដល់កំណើនសេដ្ឋកិច្ចសម្រាប់បណ្ដាប្រទេសមានសេដ្ឋកិច្ចកំពុងរីកលូតលាស់។ សហគ្រាសខ្នាតតូច និងមធ្យម ក៏ជម្រុញផងដែរដល់ការបង្កើតការងារនៅទូទាំងប្រទេស។[1]សន្ទុះកំណើនចំនួនសហគ្រាសខ្នាតតូច និងមធ្យម ជាហេតុធ្វើឲ្យ ការធ្វើចំណាកស្រុករកការងារទៅកាន់ប្រទេសជិតខាង និងអត្រាគ្មានការងារបានថយចុះគួរឲ្យកត់សម្គាល់ ដែលជាលទ្ធផលបណ្ដាលឲ្យមានការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។[2] ដូចគ្នាទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរ សហគ្រាសខ្នាតតូច និងមធ្យមគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា ដែលនេះបានរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ សហគ្រាសខ្នាតតូច និងមធ្យមក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការ៖ (១)បង្កើតការងារ (២)បង្កើតប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប និងប្រជាជនងាយរងគ្រោះ និង(៣)ជម្រុញកំណើនសេដ្ឋកិច្ច ស្ថេរភាពសង្គម និងរួមចំណែកដល់ការរីកចម្រើននៃវិស័យឯកជនយ៉ាងខ្លាំង។[3] របាយការណ៍ស្ថិតិប្រចាំឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបច្ចុប្បន្នត្រូវបានប្ដូរឈ្មោះមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានបង្ហាញថាសហគ្រាសខ្នាតតូច និងមធ្យម ដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ខណៈដែលវាបានបង្កើតការងារស្មើនឹងចំនួន៧០% នៃការងារសរុប៩៩,៨% នៃចំនួនក្រុមហ៊ុនសរុប និងរួមចំណែក៥៨% នៃផលិតផលក្នុងស្រុកសរុប (GDP)។ ដោយសារការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមមានសារៈសំខាន់ចំពោះការរក្សាកំណើន និងភាពរឹងមាំសេដ្ឋកិច្ចរបស់កម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញការប្ដេជ្ញាចិត្តរបស់ខ្លួនក្នុងការគាំទ្រដល់កំណើនពីវិស័យឯកជន និងបានដាក់ចេញនូវគោលនយោបាយជាបន្តបន្ទាប់ដែលផ្ដោតទៅលើការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម។ ក្នុងចំណោមគោលនយោបាយទាំងនោះ គឺការបង្កើតអនុគណៈកម្មាធិការសហគ្រាសខ្នាតតូច និងមធ្យមនៅឆ្នាំ២០០៤ ដែលជាស្ថាប័នចម្បងដើម្បីរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ។[4]

---

[1] Kenskin, H. , Senturk, C. , Sungur, O. & Kiris, M.K., «សារៈសំខាន់នៃសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច», សន្និសីទអន្តរជាតិលើកទី ២ ស្ដីពីការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០១០ ទំព័រទី ១៨៣-១៩២ ។

[2] ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)., «គម្រោងពង្រឹងយុទ្ធសាស្ត្រសហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០១៥ ទំព័រទី១

[3] ធនាគារពិភពលោក.,«ស្វែងយល់ពីតម្រូវការសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាសម្រាប់សេវាកម្មនិងផលិតផល ហិរញ្ញវត្ថុ (អង់គ្លេស)» ឆ្នាំ២០១០។

[4] សហគ្រាសខ្នាតតូចនិងមធ្យ(SME)«https://opendevelopmentcambodia.net/km/topics/small-and-medium-enterprises-sme/»ឆ្នាំ២០២០។

សមិទ្ធផលសំខាន់នៃអនុគណៈកម្មាធិការសហគ្រាសខ្នាតតូច និងមធ្យម គឺក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និង មធ្យម ដែលត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ ហើយត្រូវបានប្រកាសជាផ្លូវការដោយរដ្ឋាភិបាលនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៦។ ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមមានគោលបំណង *«បង្កើតបរិយាកាសធុរកិច្ចអំណោយផលមួយ ដែលនឹងនាំឲ្យវិស័យសហគ្រាសខ្នាតតូច និងមធ្យមចូលរួមចំណែកដល់ការបង្កើតការងារដែលមានគុណភាព និងលើកកម្ពស់ឲ្យមានការផលិតទំនិញ និងសេវាកម្មចម្រុះក្នុងការបម្រើដល់តម្រូវការរបស់ប្រជាជនកម្ពុជា»*។[5]

ប្រទេសកម្ពុជា ចាត់ថ្នាក់សហគ្រាសជាចំនួន៤ប្រភេទគឺ មីក្រូសហគ្រាស សហគ្រាសខ្នាតតូច ខ្នាតមធ្យម និងសហគ្រាសខ្នាតធំ។ មីក្រូសហគ្រាសត្រូវបានមើលឃើញថា មិនមានលក្ខណៈជាប្រព័ន្ធ និងគ្របដណ្តប់លើវិស័យសហគ្រាសខ្នាតតូច និងមធ្យមនោះទេ។[6] ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ដែលបង្កើតឡើងដោយអនុគណៈកម្មាធិការសហគ្រាសខ្នាតតូច និងមធ្យមនៃគណៈកម្មាធិការដឹកនាំវិស័យឯកជន ចាត់ថ្នាក់សហគ្រាសខ្នាតតូច និងមធ្យមទៅតាមចំនួននិយោជិក (ផ្អែកលើនិយោជិកដែលធ្វើការពេញម៉ោង) និងទំហំនៃទ្រព្យសកម្មនៃសហគ្រាស។ ផ្អែកលើរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានបង្ហាញថាចំនួនសហគ្រាសខ្នាតតូច និងមធ្យម មានចំនួនសរុប ១៥ ៧០៧ និងសហគ្រាសខ្នាតធំមានចំនួនសរុប ១ ៥២២។[7]

ស្របពេលគ្នានេះដែរ មីក្រូសហគ្រាសដែលមាននិយោជិកតិចជាង១០ មានចំនួន ១៣៩ ៩៣៣នាក់។ អ្វីដែលគួរកត់សម្គាល់នោះគឺ កម្លាំងពលកម្មរបស់ស្ត្រីមានចំនួនច្រើនជាងបុរសនៅគ្រប់ប្រភេទ និងទំហំនៃសហគ្រាស ខណៈអាជីវកម្មដែលកាន់កាប់ដោយស្ត្រីមានចំនួនតិចតួចនៅក្នុងវិស័យឧស្សាហកម្ម។[8]

សហគ្រាសខ្នាតតូច និងមធ្យមភាគច្រើនជាវិនិយោគក្នុងស្រុក និងមានលក្ខណៈបម្រើឲ្យការប្រើប្រាស់ក្នុងស្រុក។ ខណៈដែលសហគ្រាសខ្នាតធំ ឬឧស្សាហកម្មធុនធ្ងន់ គឺភាគច្រើនជាប្រភេទវិនិយោគបរទេស ដែលជាទូទៅផ្តោតសំខាន់លើសកម្មភាពនាំចេញ។[9]

ក្រុមហ៊ុនក្នុងវិស័យនាំចេញភាគច្រើនជាសហគ្រាសខ្នាតមធ្យម និងធុនធំ ហើយចូលរួមក្នុងវិស័យវាយនភ័ណ្ឌ សម្លៀកបំពាក់ និងការផលិតស្បែកជើង។ចំណែកឯមីក្រូសហគ្រាស និងសហគ្រាសខ្នាតតូច ចូលរួមជាចំបង

[5] Japhta, Rubin; Vizcarra, Vanessa; Bui, Thuy Thu; Yogi, Nyoman; Mel, Sokim., «ស្វែងយល់ពីឱកាសសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលគ្រប់គ្រងដោយស្ត្រីនៅកម្ពុជា (អង់គ្លេស)» ឆ្នាំ២០១៩ ទំព័រទី១២។

[6] ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) «គម្រោងពង្រឹងយុទ្ធសាស្ត្រសហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០១៥ ទំព័រទី១។

[7] រាជរដ្ឋាភិបាលកម្ពុជា «ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ ២០០៥។

[8] ក្រសួងកិច្ចការនារី., «ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី» របាយការណ៍សង្ខេប ឆ្នាំ២០១៤, ទំព័រទី៤-៧។

[9] រាជរដ្ឋាភិបាលកម្ពុជា., «គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥ - ២០២៥» ឆ្នាំ២០១៥.

ក្នុងវិស័យកែច្នៃអាហារ។ នៅឆ្នាំ ២០១៧ បើបូករួមបញ្ចូលគ្នារវាង មីក្រូសហគ្រាស សហគ្រាសខ្នាតតូច និងមធ្យម សហគ្រាសទាំងអស់នេះបានបង្កើតការងារជាងមួយលានកន្លែង ខណៈដែលសហគ្រាសខ្នាតធំ បានបង្កើតការងារជិតមួយលានកន្លែងផងដែរ។[10] យោងតាមស្ថិតិសហគ្រាសខ្នាតតូច និងមធ្យមនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងវិស័យកម្មន្តសាល ព័ត៌មានខាងក្រោមបានប្រៀបធៀបចំណែកគ្រប់វិស័យកម្មន្តសាលនៃសហគ្រាសទាំងអស់ ដែលរួមមានមីក្រូសហគ្រាស សហគ្រាសខ្នាតតូច មធ្យម និងសហគ្រាសខ្នាតធំ។ នៅឆ្នាំ២០១៦ វិស័យកម្មន្តសាលភាគច្រើនត្រូវបានគេមើលឃើញថា ប្រមូលផ្ដុំនៅក្នុងការផលិតកម្មម្ហូបអាហារ ភេសជ្ជៈ និងផលិតផលថ្នាំជក់ ដែលមានចំនួនស្មើនឹង ៨០,៣៩% នៃវិស័យកម្មន្តសាលទាំងអស់។[11]

**ចំណែកគ្រប់គ្រងវិស័យកម្មន្តសាលនៃសហគ្រាសទាំងអស់ក្នុងឆ្នាំ ២០១៦**(%)




ប្រភពៈ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម[12]

សហគ្រាសធុនតូច និងមធ្យម បង្កើតបានជាក្រុមវិភាគមួយ ហើយធ្វើការនៅក្នុងវិស័យអាជីវកម្មផ្សេងៗគ្នា។ យោងតាមជំរឿនសេដ្ឋកិច្ចកម្ពុជា គិតត្រឹម២០១១ សហគ្រាសនៅប្រទេសកម្ពុជាមានចំនួនសរុប ៥០៥ ១៣៤ គ្រឹះស្ថាន ដែលក្នុងនោះ ១០ ៨០៩ គ្រឹះស្ថាន គឺជាសហគ្រាសធុនតូច និងមធ្យម។ ជិតបីភាគបួននៃចំនួនសហគ្រាសធុនតូចនិងមធ្យម បានចុះបញ្ជីពាណិជ្ជកម្មហើយចំនួននៅសេសសល់ ជាក្រុមហ៊ុនក្រៅផ្លូវការ។

[10]Layhy, C., «ស្ថានភាពបច្ចុប្បន្នរបស់សហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា៖ បញ្ហាហិរញ្ញវត្ថុរបស់មីក្រូ សហគ្រាស សហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០១៩, ទំព័រទី៣។

[11] នាយកដ្ឋានសហគ្រាសខ្នាតតូច និងមធ្យម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម., «ស្ថិតិសហគ្រាសខ្នាតតូច និងមធ្យមនិងមីក្រូសហគ្រាស» ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧។

[12] ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ជារួមសហគ្រាសធុនតូច និងមធ្យម បានផ្តល់នូវការងារដោយសហគ្រាសធុនតូចនិងមធ្យមនីមួយៗ មានលក្ខណៈតិចតួច ពោលគឺ ភាគច្រើនបំផុតមាននិយោជិតពី ២១ នាក់ ដល់ ៣០ នាក់ (៨០.៧%) ខណៈពេលដែលប្រភេទធំបំផុតទីពីរមានចំនួននិយោជិតពី ២១ នាក់ ដល់ ៣០ នាក់ (ស្មើនឹង ១៧.៦%)។ លើសពីនេះទៅទៀត ពាក់កណ្តាលនៃសហគ្រាសធុនតូច និងមធ្យម (៥៤.៣%) ត្រូវបានបង្កើតឡើងនៅទសវត្សចុងក្រោយ។

នេះដែលជាការណ៍បង្ហាញថាស្ថានភាពពាណិជ្ជកម្មនៅប្រទេសកម្ពុជា មានការកើនឡើងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។

តារាង៖ ចំនួនគ្រឹះស្ថាននៅកម្ពុជាជាមួយនឹងចំនួនគ្រឹះស្ថានដែលបានចុះបញ្ជី និងចំនួននិយោជិត

| | សរុប | មីក្រូ | តូច និង មធ្យម | ធំ |
|---|---|---|---|---|
| ចំនួនគ្រឹះស្ថាន | ៥០៥ ១៣៤ | ៤៩៣ ៥៤៤ | ១០ ៨០៩ | ៧៨១ |
| ចំនួនគ្រឹះស្ថានចុះបញ្ជី | ៣៤ ២១២ | ៣០ ៧៨០ | ៧៦៨៨ | ២៤៤ |
| ភាគរយនៃគ្រឹះស្ថានចុះបញ្ជី | ៧.៧៦% | ៦.២៤% | ៧១.១២% | ៩៥.២៦% |
| ចំនួននិយោជិតតាមមាត្រដ្ឋាន | ១ ៦៧៣ ៣៩០ | ៩៧៥ ៩៨០ | ២៤៥ ៦៧១ | ៤៥១.៧៣៩ |

ប្រភព: ការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា ឆ្នាំ២០១៥[13]

នៅប្រទេសកម្ពុជា ពុំទាន់មានក្របខណ្ឌគតិយុត្តិ ឬបទប្បញ្ញត្តិណាមួយ ចំពោះសហគ្រាសធុនតូចនិងមធ្យមជាពិសេសនោះទេ។ ដូចនេះ សហគ្រាសធុនតូចនិងមធ្យម ត្រូវបានគ្រប់គ្រងដោយក្របខណ្ឌច្បាប់ពាណិជ្ជកម្មទូទៅ ដែលមានជាធរមាននៅក្នុងប្រទេស។

ក្នុងចំណោមក្របខណ្ឌច្បាប់ទាំងនោះ ច្បាប់ និង បទប្បញ្ញត្តិធំៗ ដែលពាក់ពន្ធ័នឹងសហគ្រាសធុនតូច និង មធ្យម រួមមានច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពផលិតផលនិងសេវាកម្ម ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ក្ស័យធន។

មុននឹងសហគ្រាសធុនតូចនិងមធ្យម អាចប្រតិបត្តិការដោយស្របច្បាប់ ដោយអនុលោមតាមក្របខណ្ឌគតិយុត្តិនិងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា សហគ្រាសធុនតូចនិងមធ្យម ត្រូវតែគោរពតាមនីតិវិធី និងកាតព្វកិច្ចមួយចំនួន ដូចជាការបំពេញការចុះបញ្ជីពាណិជ្ជកម្មជាមួយនឹងអាជ្ញាប័ណ្ណនិងលិខិតអនុញ្ញាតដែលពាក់ពន្ធ័នឹងសកម្មភាពអាជីវកម្ម និងរក្សានូវអនុលោមតាមច្បាប់ក្រុមហ៊ុន ដែលជាកម្មវត្ថុនៃអធិការកិច្ច។ ដំណើរ

[13] ការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា ឆ្នាំ២០១៥

ការដូចគ្នានេះ ក៏ត្រូវអនុវត្តផងដែរចំពោះការបិទអាជីវកម្ម។ ផ្នែកខាងក្រោមនេះ និងផ្តល់នូវទិដ្ឋភាពទូទៅនៃនីតិវិធី និងកាតព្វកិច្ចទាំងនោះ។[14]

- **ការចុះបញ្ជីពាណិជ្ជកម្ម**

យោងតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា រាល់អាជីវកម្មទាំងអស់ត្រូវចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬតាមរយៈមន្ទីរពាណិជ្ជកម្មខេត្តឬក្រុង ឬទីតាំងដ៏ទៃទៀតដែលត្រូវកំណត់ដោយក្រសួង។ ចាប់តាំងពីការអនុម័តក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម នៅឆ្នាំ ២០០៥ មកចំនួននៃក្រុមហ៊ុនដែលបានចុះបញ្ជី មានការកើនឡើងជារៀងរាល់ឆ្នាំ។ រហូតដល់ឆ្នាំ២០១១ ៧១.១២% នៃចំនួនសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជាទាំងអស់ បានចុះបញ្ជីពាណិជ្ជកម្ម (វិទ្យាស្ថានជាតិ ស្ថិតិ ឆ្នាំ២០១៣)។ កត្តានេះកើតឡើងដោយហេតុថា រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយរយៈពេលចុះបញ្ជី ដើម្បីការលើកចិត្តដល់សហគ្រិនទាំងអស់ ជាពិសេសម្ចាស់សហគ្រាសធុនតូចនិងមធ្យមក្នុងការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនពួកគេ ហើយនិងប្តូរសហគ្រាសធុនតូចនិងមធ្យមរបស់ពួកគេពីវិស័យក្រៅផ្លូវការមកជាវិស័យផ្លូវការ។ កំណែទម្រង់នៃនីតិវិធីពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មរបស់សហគ្រាសធុនតូចនិងមធ្យម ត្រូវបានធ្វើឡើងនាពេលថ្មីៗនេះ បន្ទាប់ពីការប្រជុំលើកទី ១៧ របស់វេទិការដ្ឋានភិបាល ផ្នែកឯកជន ដែលធ្វើឡើងនៅ ខែមីនា ឆ្នាំ២០១៤។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានប្រគល់ការទទួលខុសត្រូវផ្តាច់មុខលើការសម្រួលជាមួយនឹងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំនីតិវិធីឲ្យមានលក្ខណៈសាមញ្ញា និងបន្ថយនូវផលលំបាកដែលប្រឈមដោយសហគ្រាសធុនតូចនិងមធ្យម។ ជាមួយនឹងកំណែទម្រង់នេះ រយៈពេលនៃការចុះបញ្ជីពាណិជ្ជកម្មត្រូវបានកាត់បន្ថយជាមធ្យមមកត្រឹមប្រហែលជា បី ទៅ ប្រាំ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីដាក់នូវឯកសារតម្រូវទាំងអស់។ នាពេលបច្ចុប្បន្ននេះ ក្រសួងក៏កំពុងធ្វើការដាក់ចេញនូវនីតិវិធីចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធើណេតផងដែរ។ ឯកសារដែលតម្រូវសម្រាប់ចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ក៏ត្រូវបានកាត់បន្ថយផងដែរ។ បន្ថែមពីនេះទៀត តម្រូវការនៃលិខិតថ្កោលទោស និងលិខិតបញ្ជាក់អាស័យដ្ឋានរបស់ក្រុមហ៊ុន មិនតម្រូវឲ្យមានទៀតទេ។ ដើមទុនតម្រូវឲ្យមានក្នុងទម្រង់ជាលិខិតបញ្ញើប្រាក់នៅធនាគារសម្រាប់ចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ក៏ត្រូវបានកាត់បន្ថយពី ២០លានរៀល មកត្រឹម ៤លានរៀល។ នាពេលបច្ចុប្បន្ន តម្លៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មមានចំនួន ១.៨លាន រៀល និងតម្លៃរដ្ឋបាលសម្រាប់ក្រុមហ៊ុនឯកកម្មសិទ្ធិគឺ ៣០ម៉ឺនរៀល។

[14] ការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា ឆ្នាំ២០១៥

- **អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត្ត**

វាជាការលំបាកណាស់សម្រាប់ពាណិជ្ជកម្មថ្មី ដើម្បីឲ្យដឹងថាអាជ្ញាប័ណ្ណអ្វីខ្លះដែលតម្រូវឲ្យមាន។ ពិតណាស់អាជ្ញាប័ណ្ណ មានជាង ៧៥ ប្រភេទ និងអាចអនុវត្តចំពោះសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជា ហើយអាជ្ញាប័ណ្ណទាំងនេះ ត្រូវបានចេញដោយក្រសួងផ្សេងៗគ្នា ទៅតាមវិស័យពាណិជ្ជកម្ម។ គេហទំព័រអនុគណៈកម្មការនៃសហគ្រាសធុនតូចនិងមធ្យម ដែលមានផ្ទុកព័ត៌មានទាំងអស់ ដែលពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណចំពោះសហគ្រាសធុនតូចនិងមធ្យម ត្រូវបានរាយនាមជាបញ្ជី។

នាពេលថ្មីៗនេះ រដ្ឋាភិបាលកំពុងតែមានភាពសកម្មនៅក្នុងការលើកកំពស់សេវាកម្មតាមប្រព័ន្ធអ៊ិនធើណេត ដើម្បីសម្រួល និងបង្កើនល្បឿន នៃនីតិវិធីរដ្ឋបាលសម្រាប់ការស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត្ត។

- **ការចុះបញ្ជីពន្ធដារ និងកាតព្វកិច្ចចុះបញ្ជីផ្សេងៗទៀត**

បន្ទាប់ពីការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬ ទទួលបានការចុះបញ្ជីពាណិជ្ជកម្មពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលធានានូវដំណើរការចុះបញ្ជីសម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយមានរយៈពេល ១៤ថ្ងៃ ដើម្បីចុះបញ្ជីពន្ធរបស់ខ្លួន។ នីតិវិធីអាចខុសគ្នាទៅតាមទំហំ ចំណូលនិងរបរពន្ធ ដែលសហគ្រាសធុនតូច និងមធ្យមមានអត្តិភាព។

ស្របតាមច្បាប់ការងារ សហគ្រាសធុនតូចនិងមធ្យម ដែលជួលបុគ្គលិកឲ្យបំរើការនៅប្រទេសកម្ពុជា ត្រូវចុះបញ្ជីជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មុននឹងចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

- **អធិការកិច្ច**

នៅពេលចុះបញ្ជីពាណិជ្ជកម្មដើម្បីប្រតិបត្តិការនៅប្រទេសកម្ពុជារួចដូចជាអាជីវកម្មផ្សេងទៀតដែលសហគ្រាសធុនតូចនិងមធ្យម ត្រូវគោរពទៅតាមដំណាក់កាលក្រោមនៃបទប្បញ្ញត្តិកម្ពុជា ដែលពាក់ព័ន្ធនឹងការអនុលោមច្បាប់របស់ក្រុមហ៊ុន៖

1. ការប្រកាសប្រតិវេទ៍ប្រចាំឆ្នាំ៖ វាជាការប្រកាសប្រតិវេទ៍ចុងឆ្នាំនៃឆ្នាំសារពើពន្ធលើស្ថានភាពជាដៃគូអាជីវកម្មរបស់ក្រុមហ៊ុនទៅដល់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដែលនៅទីនោះ គម្រូនៃបែបប្រកាសប្រតិវេទ៍ប្រចាំឆ្នាំអាចត្រូវទទួលយកបាន។
2. ការថែរក្សាប្រព័ន្ធគណនេយ្យឲ្យត្រឹមត្រូវ៖ សហគ្រាសទាំងអស់ ត្រូវបានតម្រូវឲ្យថែរក្សា និងរៀបចំនូវកំណាត់ត្រាហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (ចាប់ផ្តើមពីថ្ងៃទី ០១ មករា នឹងបញ្ចប់ថ្ងៃទី៣១ ធ្នូ ជារៀងរាល់ឆ្នាំ)។ កំណាត់ត្រា ត្រូវធ្វើជាប្រាក់រៀលខ្មែរ និងជាភាសាខ្មែរ ហើយត្រូវផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងរយៈពេល ៣ ខែ បន្ទាប់ពីការបិទឆ្នាំសារពើពន្ធ។ ទោះជាយ៉ាងណាក៏ដោយ

សហគ្រាសធុនតូច និងមធ្យម មិនជាប់កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមបែបស្តង់ដារប្រទេសកម្ពុជា ដូចជាអ្វីដែលបានតម្រូវសម្រាប់ក្រុមហ៊ុនធំឡើយ។

3. ការបង់ពន្ធ៖ ជាទូទៅមានពន្ធធំៗបួនដែលសហគ្រាសធុនតូចនិងមធ្យម ត្រូវតែបង់ ពោលគឺពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក (តម្រូវឲ្យអ្នកបង់កាត់ទុកភាគរយនៃការបង់ប្រាក់ពីអ្នកទទួលបង់ពីព្រោះប្រព័ន្ធប្រមូលពន្ធនាពេលបច្ចុប្បន្ននោះ មិនមានយន្តការដើម្បីប្រមូលដោយផ្ទាល់ពីបុគ្គលទេ) ពន្ធលើតំលៃអាករបន្ថែម និងពន្ធលើប្រាក់ចំណូល។
4. ការសុំបន្តអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតថ្មី៖ សហគ្រាសធុនតូច និងមធ្យម ត្រូវស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតជាថ្មី។ នីតិវិធីត្រូវធ្វើឡើងនៅក្រសួង និងស្ថាប័នពាក់ព័ន្ធដូចនៅពេលដំណើរការចុះបញ្ជីដែរ។
5. ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការផ្លាស់ប្តូររចនាសម្ព័ន្ធក្រុមហ៊ុន៖ ការនេះជាកាតព្វកិច្ច ដែលសហគ្រាសធុនតូចនិងមធ្យម ត្រូវជូនដំណឹងដល់ក្រសួងពាណិជ្ជកម្មនៅពេលដែលមានការផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងក្រុមហ៊ុន ដូចជាវិសោធនកម្មលក្ខន្តិកៈក្រុមហ៊ុន ឬក្នុងករណីក្រុមហ៊ុនបញ្ចូលគ្នា ឬការទិញក្រុមហ៊ុន។

ដើម្បីធានាការអនុលោមតាមច្បាប់ក្រុមហ៊ុនទាំងអស់នេះ ភ្នាក់ងាររដ្ឋាភិបាលត្រូវធ្វើអធិការកិច្ចពីព្រោះការបរាជ័យក្នុងការអនុលោមតាមកាតព្វកិច្ចទាំងនេះ អាចនាំឲ្យសហគ្រាសធុនតូចនិងមធ្យមប្រឈមនឹងការផាកពិន័យ និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

ក្រៅពីអធិការកិច្ចទាំងអស់ទាំងនេះ សហគ្រាសធុនតូចនិងមធ្យមខ្លះ ក៏ត្រូវជាកម្មវត្ថុនៃការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មរបស់ខ្លួនដែរ។ ឧទាហរណ៍៖ សហគ្រាសធុនតូច និងមធ្យម នៅក្នុងវិស័យសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ ឬកម្មន្តសាល ជាធម្មតា តែងតែមានការធ្វើអធិការកិច្ចផ្នែកអនាម័យពីក្រសួងសុខាភិបាល។

- **ការបិទក្រុមហ៊ុន**

ម្ចាស់សហគ្រាសធុនតូច និងមធ្យម អាចរំលាយក្រុមហ៊ុនរបស់ខ្លួនជាផ្លូវការ (មានន័យថាក្រុមហ៊ុនអាចបញ្ឈប់ភាពជានីតិបុគ្គល) ដោយស្នើសុំទៅក្រសួងពាណិជ្ជកម្ម។ សំណើរត្រូវបានផ្ញើទៅម្ចាស់បំណុល និងម្ចាស់ភាគហ៊ុនទាំងអស់សម្រាប់ទូទាត់បំណុលខ្លះៗ ឬបំណុលទាំងស្រុងរបស់ក្រុមហ៊ុន ក្នុងរយៈពេលជាក់លាក់ណាមួយ។ កត្តានេះអនុញ្ញាតជាញឹកញាប់ ឲ្យក្រុមហ៊ុនបន្តសកម្មភាពពាណិជ្ជកម្មរបស់ខ្លួនបាន។ ហើយវាក៏អាចឲ្យក្រុមហ៊ុនជៀសវាងនូវតម្រូវការដំណើរការបិទក្រុមហ៊ុនតាមរយៈការជម្រះបញ្ជី។ ដំណើរការនេះ ត្រូវចំណាយពេល ប្រាំថ្ងៃនៃថ្ងៃធ្វើការ ដើម្បីដាក់ឯកសារ និងចេញនូវលិខិតលុបឈ្មោះពីការចុះបញ្ជីពាណិជ្ជកម្ម។[15]

[15] ការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា ឆ្នាំ២០១

## ១.២. និយមន័យនៃពាក្យការគ្រប់គ្រងអាជីវកម្មធុនតូច

និយមន័យសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា គឺមានភាពខុសប្លែកគ្នាពីបណ្តាប្រទេសអាស៊ាន ទាក់ទងនឹងសូចនាករសំខាន់ៗមួយចំនួន។ ឧទាហរណ៍ នៅប្រទេសហ្វីលីពីន និយមន័យត្រូវបានកំណត់ដោយទ្រព្យអកម្ម ដែលជាលក្ខណៈវិនិច្ឆ័យសម្រាប់សម្គាល់ទំហំនៃសហគ្រាស។ ដោយឡែកប្រទេសឥណ្ឌូនេស៊ីប្រើប្រាស់ទ្រព្យសកម្ម និងការលក់ប្រចាំឆ្នាំ ខណៈដែលប្រទេសវៀតណាមកំណត់និយមន័យសហគ្រាសខ្នាតតូច និងមធ្យមទៅតាមចំនួននិយោជិក និងតម្លៃសរុបនៃដើមទុនរបស់សហគ្រាសនោះ។ នៅប្រទេសឡាវ និយមន័យមីក្រូសហគ្រាសត្រូវបានកំណត់នៅពេលសហគ្រាសមានចំនួននយោជិក៥នាក់ ឬតិចជាងនេះ។

ជាការពិតណាស់សហគ្រាសខ្នាតតូច និងមធ្យម ដែលគេនិយមហៅកាត់ថា**MSMEs (Micro Small and Medium Enterprises)** ការកំណត់និយមន័យគេអាចបែងចែកតាមចំនួននិយោជិក ទ្រព្យសកម្មរបស់ក្រុមហ៊ុន ហើយខ្លះទៀតផ្អែកទៅតាមទំហំនៃចំណូលប្រចាំខែ ឬប្រចាំឆ្នាំរបស់គេ។

មុនឆ្នាំ២០០៥ កម្ពុជាពុំមាននិយមន័យសមូហភាពនៃសហគ្រាសខ្នាតតូច និងមធ្យមនៅឡើយទេ រវាងនិយមន័យពីវិទ្យាស្ថានជាតិស្ថិតិ (NIS) និងពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម (ដែលពីមុនស្ថិតនៅក្នុងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល)។ រហូតមកដល់ខែកក្កដា ឆ្នាំ២០០៥ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការបានចាត់ថ្នាក់សហគ្រាសដែលមានបុគ្គលិកមិនលើសពី១០នាក់ជាសហគ្រាសខ្នាតតូច និង១១នាក់ឡើងទៅជាសហគ្រាសខ្នាតធំ ហើយបន្ទាប់ពីនោះក៏មានការចាត់ថ្នាក់បន្ថែមពីនោះទៀតថា សហគ្រាសធុនមធ្យមមានបុគ្គលិកចាប់ពី១១នាក់ដល់១០០នាក់។ ហើយស្របពេលជាមួយគ្នានោះដែរ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានកំណត់សហគ្រាសធុនតូចមានបុគ្គលិកតិចជាង៥០នាក់។

នៅឆ្នាំ២០០៥ អនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យមបានស្នើការចែកចំណាត់ថ្នាក់ដូចខាងក្រោម៖

**តារាង៖ និយមន័យ MSMEs នៅកម្ពុជា**

| **ចំណាត់ថ្នាក់** | **ចំនួនបុគ្គលិក(នាក់)** | **ទ្រព្យសកម្ម(មិនរាប់បញ្ចូលដី និងគិតជាដុល្លាអាមេរិក)** |
|---|---|---|
| សហគ្រាសមីក្រូ | <១០ | <៥០,០០០ |
| សហគ្រាសខ្នាតតូច | ១០-៥០ | ៥០,០០០-២៥០,០០០ |
| សហគ្រាសខ្នាតមធ្យម | ៥១-១០០ | ២៥០,០០០-៥០០,០០០ |
| សហគ្រាសខ្នាតធំ | >១០០ | >៥០០,០០០ |

ប្រភព:ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម (២៩ កក្កដា ២០០៥)[16]

[16] ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម (២៩ កក្កដា ២០០៥)

ប្រទេសកម្ពុជា ត្រូវបានលើកលែងឲ្យកំណត់និយមន័យដោយប្រើប្រាស់ដុល្លាអាមេរិច សម្រាប់ការរៀបចំគោលនយោបាយ និងស្ថិតិ នៅពេលចំនួនបុគ្គលិកមិនសមស្រប។ ហើយចំណាត់ថ្នាក់ MSMEs ដែលបែកចែកខាងលើគ្របដណ្តប់តែវិស័យឧស្សាហកម្ម និងសិប្បកម្មប៉ុណ្ណោះ។

ក្រោយមករាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៧ អនក្រ. បក ចុះ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីពន្ធលើសហគ្រាសខ្នាតតូចនិងមធ្យម និងបានផ្តល់និយមន័យនៃសហគ្រាសធុនតូច និងមធ្យមដូចខាងក្រោម៖

- សហគ្រាសខ្នាតតូច ជាសហគ្រាសដែលមានចំណូលប្រចាំឆ្នាំពី២៥០លាន ទៅ៧០០លានរៀល
- សហគ្រាសខ្នាតមធ្យម ជាសហគ្រាសមានចំណូលប្រចាំឆ្នាំពី៧០០លាន ទៅ២០០០លានរៀល

និយមន័យនេះត្រូវបានកំណត់គ្របដណ្តប់លើគ្រប់វិស័យ ហើយរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមប្រើប្រាស់ប្រាក់រៀលខ្មែរក្នុងបែងចែកដូច ប្រទេសដ៏ទៃដែលប្រើរូបិយវត្ថុផ្ទាល់ខ្លួនក្នុង ការកំណត់ និយមន័យនោះ។

រហូតដល់ខែតុលា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានចេញអនុក្រឹតលេខ១២៤ អនក្រ.បក ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលបានធ្វើការកែសម្រួលនិយមន័យសហគ្រាសខ្នាតតូច និងមធ្យមជាថ្មីម្តងទៀត។ ប៉ុន្តែនិយមន័យនេះមានដែនកំណត់សម្រាប់តែវិស័យអាទិភាពដែលរាជរដ្ឋាភិបាលបានកំណត់ប៉ុណ្ណោះ។

និយមន័យត្រូវបានកំណត់ដូចតារាងខាងក្រោម៖

តារាង៖ និយមន័យ MSMEs នៅកម្ពុជា

| ចំណាត់ថ្នាក់ | ចំនួនបុគ្គលិក (នាក់) | ទ្រព្យសកម្ម(មិនរាប់បញ្ចូលដី និងគិតជាលានរៀល) | ចំណូលប្រចាំឆ្នាំ(លានរៀល) |
|---|---|---|---|
| សហគ្រាសមីក្រូ | <១០ | <២០០ | <២៥០ |
| សហគ្រាសខ្នាតតូច | ១០-៥០ | ២០០-តិចជាង២៥០ | ២៥០-តិចជាង៧០០ |
| សហគ្រាសខ្នាតមធ្យម | ៥១-១០០ | ២៥០-២០០០ | ៧០០-តិចជាង២០០០ |
| សហគ្រាសខ្នាតធំ | >១០០ | >២០០០ | >២០០០ |

ប្រភពៈ ការណែនាំអនុវត្តអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព[17]

[17] ការណែនាំអនុវត្តអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព

## ១.៣. ចរិកលក្ខណៈនៃអាជីវកម្មធុនតូច

តាមនិយមន័យខាងលើបង្ហាញឲ្យឃើញថាអាជីវកម្មធុនតូចមានចរិកលក្ខណៈ ដូចខាងក្រោមដែលអាចសម្គាល់ឬកំណត់បានថាជាអាជីវកម្មធុនតូច។

- ចំនួនបុគ្គលិកមានចាប់ពី១០ទៅ៥០នាក់
- មានទុនចល័តពី៥ម៉ឺនដល់២៥ម៉ឺនដុល្លាអាមេរិច
- មានប្រាក់ចំណូលប្រចាំឆ្នាំពី២៥០លានរៀលទៅ៧០០លានរៀល

អាជីវកម្មធុនតូចមានតួនាទីយ៉ាងសំខាន់ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់ប្រទេសជាតិ ហើយបានចូលរួមចំណែកលើកកម្ពស់ដល់ជីវភាពរស់នៅរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រ។ នៅកម្ពុជាមានអាជីវកម្មធុនតូចជាង៩០%នៃសហគ្រាសសរុបនៅកម្ពុជា និងចូលរួមផ្តល់ផ្គង់ផលិតផលនៅកម្ពុជា ហើយក៏បានផ្តល់ឱកាសការងារសម្រាប់ប្រជាជនកម្ពុជាទូទាំងរាជធានីខេត្ត ហើយជាពិសេសរួមចំណែកបង្កើនផលចំណូលសរុបក្នុងស្រុក ក៏ដូចជាជម្រុញការនាំចេញ។ អាជីវកម្មធុនតូចនៅកម្ពុជាក៏ដូចជាប្រទេសផ្សេងៗលើសាកលលោកផងដែរ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញកំណើន និងស្ថេរភាពសេដ្ឋកិច្ច និងសង្គមយ៉ាងមានប្រសិទ្ធភាព។

នៅពេលដែលសេដ្ឋកិច្ចកាន់តែរីកចម្រើន ទំហំនៃតម្រូវការប្រចាំថ្ងៃក៏កាន់តែធំផងដែរ ហើយអាជីវកម្មធុនតូចមានតួនាទីផ្គត់ផ្គង់ផលិតផលផ្សេងៗតាមតម្រូវការទាំងនោះ ដូចជា អាហារ ជម្រក សម្លៀកបំពាក់ ការធ្វើដំណើរ និងផលិតផលផ្សេងៗទៀត។ ហើយទីផ្សារក្នុងស្រុកទាំងនេះមិនត្រូវការស្តង់ដារអន្តរជាតិនោះទេ ដែលអាចឲ្យអាជីវកម្មធុនតូចឈានជើងចូលទីផ្សារបានយ៉ាងងាយស្រួល។

## ១.៤. តួនាទីរបស់ស្ថាប័នរដ្ឋក្នុងការជួយអាជីវកម្មធុនតូច

### ១.៤.១. គោលនយោបាយ និងការអនុវត្តភាពនៃសហគ្រាសខ្នាតតូច និងមធ្យម

ប្រទេសកម្ពុជាមិនទាន់មានច្បាប់ជាក់លាក់ណាមួយដើម្បីគ្រប់គ្រងសហគ្រាសខ្នាតតូច និង មធ្យមនៅឡើយទេ។ ទោះបីជាយ៉ាងណារដ្ឋាភិបាលបានប្រកាសក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មសម្រាប់ឆ្នាំ២០០៥-២០១០ ក្រោមក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងបានបង្កើតអនុគណៈកម្មាធិការជាតិមួយសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។[18] បច្ចុប្បន្ននេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ដែលពីមុនត្រូវបានគេស្គាល់ថា ជាក្រសួងឧស្សាហកម្ម និងសិប្បកម្ម)ទទួលបន្ទុកអនុវត្តន៍គោលនយោបាយសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។

ក្របខ័ណ្ឌច្បាប់របស់សហគ្រាសខ្នាតតូច និងមធ្យមគឺបានផ្តោតសំខាន់ទៅលើឧបករណ៍គតិយុត្ត និងច្បាប់ ជាពិសេសទាក់ទងនឹងការចុះបញ្ជីអាជីវកម្ម ការទទួលបានហិរញ្ញប្បទាន ក៏ដូចជាសកម្មភាពគាំទ្រសហគ្រាស

[18] អាស៊ាន., «ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា», មិនមានថ្ងៃបរិច្ឆេទ។

ខ្នាតតូច និងមធ្យមមួយចំនួនផ្សេងទៀត។[19] គំនិតផ្តួចផ្តើមនេះត្រូវបានអនុវត្តដើម្បីកាត់បន្ថយចំនួនសហគ្រាសខ្នាតតូចនិងមធ្យមក្រៅផ្លូវការ ហើយការលើកទឹកចិត្តផ្នែកពន្ធត្រូវបានចាត់ទុកថាជាយន្តការមួយទៀតដើម្បីសម្រេចគោលបំណងនេះ។

សហគ្រាសខ្នាតតូច និងមធ្យមត្រូវចុះបញ្ជីអាជីវកម្មរបស់ខ្លួនស្របច្បាប់និងអនុវត្តន៍តាមបទប្បញ្ញត្តិជាចាំបាច់ដូចជា ការរក្សាគណនេយ្យឲ្យបានត្រឹមត្រូវដើម្បីទទួលបានអត្ថប្រយោជន៍ពីការលើកទឹកចិត្តផ្នែកពន្ធដា។ ការលើកទឹកចិត្តផ្នែកពន្ធត្រូវបានដាក់ឡើងជាការលើកទឹកចិត្តដើម្បីនាំសហគ្រាសខ្នាតតូច និងមធ្យមចូលរួមនៅក្នុងបរិយាកាសច្បាប់មួយដែលត្រឹមត្រូវ។ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ដើម្បីលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមជាអ្នកបង់ពន្ធទៅលើចំណុចដូចខាងក្រោម៖

(១) ការលើកលែងរយៈពេល២ឆ្នាំទៅលើពន្ធប្រាក់ចំណេញ សម្រាប់ការចុះឈ្មោះអាជីវកម្មស្របច្បាប់ដោយស្ម័គ្រចិត្តក្នុងឆ្នាំ ២០១៧ និង ២០១៨

(២) ពន្ធអប្បបរមាមួយភាគរយប្រចាំឆ្នាំ (និងការបង់ប្រាក់ប្រចាំខែ) ក្នុងអំឡុងពេលលើកលែងនេះ។

ម៉្យាងទៀត អនុក្រឹត្យលេខ ១២៤ អនក្រ.បក នេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី២ ខែតុលាឆ្នាំ២០១៨ ក្នុងគោលបំណងជម្រុញសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងវិស័យអាទិភាពចំនួនប្រាំមួយ រាប់ចាប់ពីការផលិតផលកសិកម្ម ដល់ផលិតផលក្នុងសេវាកម្មព័ត៌មានវិទ្យា និងសហគ្រាសដែលមានទីតាំងនៅតំបន់ចង្កោមសហគ្រាសខ្នាតតូច និងមធ្យមរួមទាំងសហគ្រាសក្នុងដំណើរការអភិវឌ្ឍន៍ទៅក្នុងចង្កោមនេះផងដែរ(SME Cluster Zones)។ ការលើកទឹកចិត្តរួមមានការលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់រយៈពេលបីឆ្នាំ សម្រាប់សហគ្រាសដែលបានចុះបញ្ជីថ្មី និងរយៈពេលប្រាំឆ្នាំ ប្រសិនបើតម្រូវការលក្ខខណ្ឌតិកៈផ្សេងទៀតត្រូវបានបំពេញគ្រប់ជ្រុងជ្រោយដោយសហគ្រាសទាំងនោះ។ ការលើកលែងពីការបង់ពន្ធមុន១% លើប្រាក់ចំណូល និងពន្ធអប្បបរមាប្រចាំឆ្នាំក្នុងកំឡុងពេលពន្ធលើរយៈពេលលើកលែងប្រាក់ចំណូលក៏អាចអនុវត្តន៍បានដែរ។[20]

អនុក្រឹត្យលេខ ១២៤ អនក្រ.បក អនុវត្តចំពោះសហគ្រាសខ្នាតតូច និងមធ្យមដែលត្រូវបានកំណត់ក្នុងបទប្បញ្ញត្តិផ្អែកលើចំនួនប្រាក់ចំណេញប្រចាំឆ្នាំ និងចំនួននិយោជិករបស់ពួកគេ។[21]

ជាទូទៅសហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានកំណត់ដោយនិយោជិកតិចជាង១០០នាក់ និងចំណូលប្រចាំឆ្នាំតិចជាង៥០ម៉ឺនដុល្លារអាមេរិក។ ក្រោមរបបពន្ធបច្ចុប្បន្ន (វាយតម្លៃដោយខ្លួនឯង ឬពិតប្រាកដ) អ្នកបង់

[19] រាជរដ្ឋាភិបាលកម្ពុជា., «ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០០៥។

[20] សហគ្រាសខ្នាតតូចនិងមធ្យ(SME)«https://opendevelopmentcambodia.net/km/topics/small-and-medium-enterprises-sme/»ឆ្នាំ២០២០។

[21] DFDL«បច្ចុប្បន្នភាពពន្ធនៅកម្ពុជា៖ សេចក្តីប្រកាសស្តីពីការលើកទឹកចិត្តពន្ធសហគ្រាសធុនតូចនិងមធ្យម», ឆ្នាំ ២០១៨។

ពន្ធត្រូវបានបែងចែកជាអ្នកបង់ពន្ធខ្នាតតូច មធ្យម និងធំ។ ប្រភេទនៃអ្នកជាប់ពន្ធក្នុងការធ្វើចំណាត់ថ្នាក់នេះ គឺខុសគ្នាពីនិយមន័យទូទៅរបស់សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជាដូចដែលបានរៀបរាប់ខាងលើ។ ដើម្បីជួយដល់ការអនុវត្តអនុក្រឹត្យលេខ ១២៤ និងចំពេលមានការរីករាលដាលនៃជំងឺកូវីដ១៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញ ប្រកាសលេខ ១៥៩ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ដោយដាក់ចេញនូវការណែនាំពីលក្ខន្តិកៈ និងនីតិវិធីដើម្បីស្នើសុំការលើកទឹកចិត្តផ្នែកពន្ធ។[22] ទីភ្នាក់ងាររដ្ឋាភិបាលដែលទើបបង្កើតថ្មី ដែលជាធនាគារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា (SME Bank) ត្រូវបានគេរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សហគ្រាសខ្នាតតូច និងមធ្យម។ ការបង្កើតធនាគារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមនេះត្រូវបានអនុម័តនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ហើយត្រូវដំណើរការជាផ្លូវការនៅដើមឆ្នាំ២០២០ ដោយមានដើមទុន១០០លានដុល្លារ ដើម្បីផ្តល់ហិរញ្ញប្បទានដល់សហគ្រាសខ្នាតតូច និងមធ្យម។[23]

យោងតាម សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធនាគារនេះកំពុងអនុវត្តន៍ «គម្រោងសហហិរញ្ញប្បទាន សម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម» ដែលមានការបណ្តាក់ទុនរួមគ្នាជាមួយធនាគារពាណិជ្ជចំនួន២៣ ធនាគារឯកទេសចំនួនពីរ និងស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួនប្រាំពីរ។[24]

### ១.៤.២. ការលើកទឹកចិត្តផ្នែកគយ សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម

ការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូចនិងមធ្យម ជាផ្នែកមួយក្នុងវិធានទី៤ នៃកញ្ចប់វិធានការកែទម្រង់មុតស្រួចចំនួន ដប់ប្រាំពីរ ដែលត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រកាសដាក់ឲ្យអនុវត្តនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ នៅវិមានសន្តិភាព ដើម្បីជម្រុញបន្ថែមការអភិវឌ្ឍន៍ ការពង្រឹងភាពប្រកួតប្រជែង និងការបង្កើនសមត្ថភាពផលិតកម្មរបស់សហគ្រាសធុនតូចនិងមធ្យម ដែលត្រូវបានចាត់ទុកជាឆ្អឹងខ្នងសេដ្ឋកិច្ច និងជាកម្លាំងចលករដ៏សំខាន់ក្នុងការជម្រុញកំណើន និងបង្កើតការងារសម្រាប់ប្រជាជន។

#### ១. លក្ខខណ្ឌដើម្បីទទួលបានការលើកទឹកចិត្តផ្នែកគយ

ដើម្បីអាចទទួលបានការលើកទឹកចិត្តផ្នែកគយ សហគ្រាសធុនតូចនិងមធ្យមត្រូវបំពេញ ០៣ល័ក្ខខ័ណ្ឌៈ

- បានចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ឬមធ្យម

[22] ក្រុមហ៊ុន KPMG Cambodia Ltd., "ការណែនាំស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម" ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។

[23] Vireak, T., «ធនាគារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម បានបើកដំណើរការជាផ្លូវការហើយ» ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០។

[24] Vireak, T., «ធនាគារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម បានបើកដំណើរការជាផ្លូវការហើយ» ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០។

- ជាសហគ្រាសធុនតូចនិងមធ្យម ស្ថិតក្នុងវិស័យអាទិភាព
- បំពេញនីតិវិធីនៃការស្នើសុំការលើកទឹកចិត្តផ្នែកគយ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ចំពោះនីតិវិធីចុះបញ្ជីពន្ធដារ សហគ្រាសធុនតូច និងមធ្យមអាចសួរនាំព័ត៌មានបន្ថែម នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**២. វិស័យអាទិភាពដែលទទួលបានការលើកទឹកចិត្តផ្នែកគយ**

ដើម្បីអាចទទួលបានការលើកទឹកចិត្តផ្នែកគយ សហគ្រាសធុនតូច និងមធ្យមត្រូវស្ថិតក្នុងវិស័យណាមួយក្នុងចំណោម ០៨ វិស័យ ខាងក្រោម៖




**៣. មុខសញ្ញានៃការលើកទឹកចិត្តផ្នែកគយ**

សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព អាចទទួលបានការលើកទឹកចិត្តផ្នែកគយចំពោះមុខសញ្ញា ដូចខាងក្រោម៖

- **សម្ភារបរិក្ខារផលិតកម្ម៖** សំដៅដល់គ្រឿងម៉ាស៊ីន ឧបករណ៍ដែលបានប្រើប្រាស់ជាមូលដ្ឋានក្នុងការបំប្លែងធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះមិនអាចបំប្លែងបានដោយខ្លួនឯង ឬមិនត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល ពីរឆ្នាំ បន្ទាប់ពីបាននាំចូល។
- **សម្ភារៈសាងសង់៖** សំដៅដល់សម្ភារៈសំណង់ រួមទាំងឧបករណ៍ បរិក្ខារ ដែលបានបំប្លែង ឬបានប្រើប្រាស់ទាំងស្រុងនៅក្នុងការសាងសង់សំណង់បម្រើឲ្យផលិតកម្ម។
- **ធាតុចូលផលិតកម្ម៖** សំដៅដល់ទំនិញ រួមទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេច និងសម្ភារៈបន្ទាប់បន្សំបម្រើឲ្យផលិតកម្ម ដែលត្រូវបំប្លែង ឬត្រូវបានប្រើប្រាស់យ៉ាងពេញលេញ នៅក្នុងកិច្ចដំណើរការផលិតកម្ម មិនឲ្យហួសរយៈពេល ២ឆ្នាំ បន្ទាប់ពីបាននាំចូល។

**សម្គាល់**៖ សម្ភារបរិក្ខារផលិតកម្ម, សម្ភារសាងសង់ និងធាតុចូលផលិតកម្ម មិនគិតបញ្ចូលនូវយានយន្ត គ្រឿងបន្លាស់យានយន្ត ផលិតផលតេលសិលា និងសម្ភារៈបរិក្ខារនិងគ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ។

### ៤. ការផ្ដល់ការលើកទឹកចិត្តផ្នែកគយ

ការលើកទឹកចិត្តផ្នែកគយសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព ត្រូវបានផ្ដល់ជូនដូចខាងក្រោម៖

- **សហគ្រាសផលិតនិងផ្គត់ផ្គង់ទឹកស្អាត៖** ត្រូវបានទទួលប្រព្រឹត្តកម្មលើកលែងពន្ធគយ ដូចនឹងសហគ្រាសបម្រើឲ្យការនាំចេញ។
- **សហគ្រាសបម្រើឲ្យការនាំចេញ៖** ត្រូវបានលើកលែងពន្ធគយ លើសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងធាតុផលិតកម្ម។ ក្នុងករណីធាតុចូលផលិតកម្មរបស់សហគ្រាសប្រភេទនេះ ត្រូវបានកែច្នៃ ហើយមិនបាននាំចេញ ត្រូវបំពេញកាតព្វកិច្ចពន្ធឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូល ក្រោយពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។
- **សហគ្រាសជាប្រភេទឧស្សាហកម្មគាំទ្រ៖** ត្រូវបានលើកលែងពន្ធគយ លើសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្ម សម្រាប់ផលិតផ្គត់ផ្គង់ដល់សហគ្រាសបម្រើឲ្យការនាំចេញ។ ក្នុងករណីធាតុចូលផលិតកម្មរបស់សហគ្រាសប្រភេទនេះត្រូវបានកែច្នៃ ហើយមិនបានផ្គត់ផ្គង់ដល់សហគ្រាសបម្រើឲ្យការនាំចេញ ឬមិនបាននាំចេញដោយផ្ទាល់ ត្រូវបំពេញកាតព្វកិច្ចពន្ធឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូល តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។
- **សហគ្រាសបម្រើតម្រូវការក្នុងស្រុក៖** ត្រូវបានលើកលែងពន្ធគយ តែលើសម្ភារបរិក្ខារផលិតកម្ម និងសម្ភារសាងសង់។ ក្នុងករណីសហគ្រាសប្រភេទនេះ មានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលផលិតដោយផ្ទាល់ បរិមាណធាតុចូលផលិតកម្មដែលបានបង់ពន្ធគយរួចយកទៅបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវទទួលបានការលើកលែងពន្ធគយ ក្រោយពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។
- **ការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន៖** ត្រូវបានលើកលែងពន្ធគយ លើសម្ភារបរិក្ខារសម្រាប់តម្លើងនិងប្រើប្រាស់ក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈនវានុវត្តន៍។
- **អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្ដុំសហគ្រាសធុនតូចនិងមធ្យម៖** ត្រូវបានទទួលបានប្រព្រឹត្តកម្មលើកលែងពន្ធគយដូចនឹងសហគ្រាសបម្រើតម្រូវការក្នុងស្រុក។[25]

[25] នីតិវិធីគយ/នីតិវិធីពិសេស http://v1.customs.gov.kh

### ១.៤.៣. ដំណោះស្រាយរបស់រដ្ឋសម្រាប់បញ្ហាប្រឈមរបស់សហគ្រាសខ្នាតតូច និងមធ្យម

ទោះបីចំនួនសហគ្រាសខ្នាតតូច និងមធ្យមដែលបានចុះបញ្ជីស្របច្បាប់មានចំនួនកើនឡើងក៏ដោយ បញ្ហាប្រឈមជាច្រើននៅតែមានចំពោះសហគ្រិន និងរដ្ឋាភិបាលនៅក្នុងអំឡុងពេលនៃរបៀបវារៈក្នុងការអភិវឌ្ឍន៍សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។ បញ្ហាប្រឈមដែលមានលើកឡើងក្នុង គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ និងការសិក្សាដទៃទៀតរួមមានៈ

- **ការទទួលបានហិរញ្ញវត្ថុ នៅតែមានផលលំបាកៈ** នៅប្រទេសកម្ពុជា ប្រមាណ៦៦%នៃសហគ្រាសបានបញ្ជាក់ថាការទទួលបានហិរញ្ញវត្ថុនៅតែជាបញ្ហាប្រឈម ហើយបញ្ហាប្រឈមចម្បងរបស់មីក្រូសហគ្រាសខ្នាតតូច និងមធ្យម គឺការទទួលបានកម្ចីទុនបង្វិល។ ទោះបីជាការទទួលបានសេវាកម្មហិរញ្ញវត្ថុមានការកើនឡើងយ៉ាងឆាប់រហ័សនៅរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ស្ទើតែមួយភាគបីនៃចំនួនប្រជាជនមិនបានប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុផ្លូវការឡើយ។ ចំណេះដឹង និងជំនាញបច្ចេកទេសគឺជាធនធាននៅមានចំនួនកំណត់នៅឡើយ ដូចជាកម្មករជំនាញដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ អ្នកបច្ចេកទេស និងវិស្វករ ដែលក្នុងន័យនេះវាបានរារាំងប្រទេសមិនឲ្យស្រូបយក និងប្រើប្រាស់បច្ចេកវិទ្យាទំនើបបានសម្រាប់ការអភិវឌ្ឍន៍ឧស្សាហកម្មរបស់ខ្លួន។

ការដោះស្រាយកង្វះនិយោជិកដែលមិនមានជំនាញ ផលិតភាពទាប ជំនាញមិនត្រូវគ្នា និងប្រាក់ឈ្នួលនៅតែបង្កជាបញ្ហាប្រឈមយ៉ាងខ្លាំងដល់ការអភិវឌ្ឍន៍បន្ថែមទៀតរបស់ប្រទេសកម្ពុជា។

- **កង្វះខាតការគាំទ្រ និងការសម្របសម្រួលពីស្ថាប័នពាក់ព័ន្ធៈ** បានរារាំងដល់ការអភិវឌ្ឍន៍ និងបរាជ័យក្នុងការដោះស្រាយកង្វល់ដែលកំពុងកើតឡើងចំពោះសហគ្រាសខ្នាតតូច និងមធ្យម។ យន្តការត្រួតពិនិត្យមួយគួរត្រូវបានបង្កើតឡើងដើម្បីដាក់សម្ពាធបន្ថែមទៀតលើស្ថាប័នទទួលខុសត្រូវ និងទីភ្នាក់ងាររដ្ឋាភិបាលឲ្យចាត់វិធានការ និងកែលម្អបរិយាកាសអាជីវកម្មសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។
- **ការប្រកួតប្រជែងតាមរយៈការពង្រីកទីផ្សារក្នុងតំបន់ និងអន្តរជាតិៈ** កំពុងកើនឡើងតាមរយៈការផ្លាស់ប្តូរនៅក្នុងបដិវត្តឧស្សាហកម្ម និងសកលភាវូបនីយកម្ម។ ការធ្វើអាជីវកម្មនៅប្រទេសកម្ពុជាគឺនៅចំណាយច្រើននៅឡើយ រាប់ចាប់តាំងពីការចាប់ផ្តើមបើកដំណើរអាជីវកម្មរហូតដល់ការបិទអាជីវកម្ម។ ហើយ កង្វះខាតកាផ្គត់ផ្គង់អគ្គិសនី ធ្វើឲ្យប្រទេសកម្ពុជាស្ថិតក្នុងភាពលំបាកមួយក្នុងការប្រកួតប្រជែងបើប្រៀបធៀបនឹងប្រទេសជិតខាង។
- **ភាពមិនផ្លូវការនៃសហគ្រាសខ្នាតតូច និងមធ្យម ជាពិសេសមីក្រូសហគ្រាសៈ** ដូចដែលបានលើកឡើងពីដំបូង មីក្រូសហគ្រាសភាគច្រើនជាអាជីវកម្មដែលគ្រប់គ្រងមានលក្ខណៈជាគ្រួសារ និងធ្វើ

ប្រតិបត្តិការក្រៅផ្លូវការដែលធ្វើឲ្យរដ្ឋាភិបាលមានការលំបាកក្នុងការប្រមូលពន្ធ រៀបរៀង និងអនុវត្ត គោលនយោបាយគាំទ្រ ដើម្បីជួយដល់សហគ្រាសទាំងអស់នោះ ក្នុងការបង្កើនតម្លៃនៃខ្សែចង្វាក់ផលិតកម្មរបស់ខ្លួន។

តាមរយៈបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលយកចិត្តទុកដាក់បន្តការគាំទ្រដល់ការលើកកម្ពស់ និងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងសហគ្រិនភាពដោយកំណត់ការផ្តោតសំខាន់លើសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងគោលនយោបាយគន្លឹះរបស់ខ្លួនដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ (ដំណាក់កាលទី៤)។ រាជរដ្ឋាភិបាលមានគោលបំណងគាំទ្រសហគ្រាសខ្នាតតូច និងមធ្យមទាក់ទងនឹងសកម្មភាពផលិតភាព ការបង្កើតការងារ សហគ្រិនភាព ភាពច្នៃប្រឌិត និងនវានុវត្តន៍ ក៏ដូចជាការលើកទឹកចិត្តសហគ្រាសឲ្យមានលក្ខណៈស្របច្បាប់ និងការរីកចម្រើនរបស់សហគ្រាសទាំងនេះព្រមទាំងការទទួលបានសេវាកម្មហិរញ្ញវត្ថុ។ គោលដៅទាំងអស់នេះត្រូវបានកំណត់នៅក្នុងគោលដៅទី៨ នៃក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០។ ដើម្បីអភិវឌ្ឍន៍ក្របខ័ណ្ឌប្រកបដោយប្រសិទ្ធភាពសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដល់សហគ្រាសខ្នាតតូច និងមធ្យម ធ្វើការចុះឈ្មោះស្របច្បាប់ដោយស្ម័គ្រចិត្ត។ នៅខែមករា ឆ្នាំ២០១៩ អង្គភាពពន្ធដារជាតិបានចេញសេចក្តីជូនដំណឹងស្តីពីការអនុវត្តអនុក្រឹត្យលេខ ១២៤ អនក្រ.បក ដែលបង្កើតការលើកទឹកចិត្តផ្នែកពន្ធដាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងវិស័យដែលបានកំណត់។[26]

## ១.៥. អត្ថប្រយោជន៍នៃអាជីវកម្មធុនតូច

សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានគេចាត់ទុកថាជាកម្លាំងជម្រុញដល់កំណើនសេដ្ឋកិច្ចសម្រាប់បណ្តាប្រទេសមានសេដ្ឋកិច្ចកំពុងរីកលូតលាស់។ សហគ្រាសខ្នាតតូច និងមធ្យមក៏បានធ្វើការជម្រុញផងដែរដល់ការបង្កើតការងារនៅទូទាំងប្រទេស។ សន្ទុះកំណើនចំនួនសហគ្រាសខ្នាតតូច និងមធ្យមបានធ្វើចំនួនប្រជាជនដែលធ្វើការចំណាកស្រុករកការងារទៅកាន់ប្រទេសជិតខាង និងអត្រាគ្មានការងារបានថយចុះគួរឲ្យកត់សម្គាល់ ដែលជាលទ្ធផលបណ្តាលឲ្យមានការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។

### ១.៥.១. ការបង្កើតការងារ និងកាត់បន្ថយនិកម្មភាពសម្រាប់កម្ពុជា

កត្តាដែលអាចឲ្យយើងអះអាងថាសហគ្រាសធុនតូច និងមធ្យមបានដើរតួរយ៉ាងសំខាន់ក្នុងការបង្កើតការងារ កាត់បន្ថយនិកម្មភាពការងារនោះគឺ ចំនួននៃសហគ្រាសធុនតូច និងមធ្យមមានចំនួនច្រើនគួរឲ្យកត់សម្គាល់។ ដោយយោងទៅតាមទិន្នន័យសហគ្រាសធុនតូច និងមធ្យមរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ

[26]សហគ្រាសខ្នាតតូចនិងមធ្យ(SME)«https://opendevelopmentcambodia.net/km/topics/small-and-medium-enterprises-sme/»ឆ្នាំ២០២០។

បច្ចេកវិទ្យា និងនវានុវត្តន៍ បានបង្ហាញថា សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាមានរហូតទៅដល់៥៣ម៉ឺនសហគ្រាស។ ដូច្នេះយើងអាចប៉ាន់ស្មាន់បានថា សហគ្រាសមួយអាចបង្កើតការងារ១០កន្លែង ដូចនេះបើទំហំរហូតទៅដល់៥៣ម៉ឺនសហគ្រាសត្រូវការកម្លាំងពលកម្មរហូតដល់៥៣០ម៉ឺនកន្លែង។ មានMSMEs នៅកម្ពុជាទាំង ៥២,១៥៤ មូលដ្ឋាន បានបង្កើតការងារសរុបចំនួន៨២៤,២៤៥ នៅឆ្នាំ២០១៩។ នៅក្នុងឆ្នាំ២០១៨ មាន MSMEs រហូតទៅដល់១៥៦,៨៥៣ មូលដ្ឋាន ហើយបង្កើតការងារបានរហូតដល់ ១,១២៣,៣៣៣ កន្លែងសម្រាប់ប្រជាពលរដ្ឋកម្ពុជា។តាមប្រសាសន៏របស់លោក ឈា ឡាយហី ប្រធាននាយកដ្ឋានសហគ្រាសធុនតូច និងមធ្យមនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានឲ្យដឹងថា *នៅកម្ពុជាជាង៥០ម៉ឺនសហគ្រាស ក្នុងនោះសហគ្រាសមីក្រូ ខ្នាតតូច និងមធ្យម ដែលមានជាង១៥ម៉ឺនសហគ្រាស បានស្រូបទាញកម្លាំងពលកម្មជាង១លាននាក់នៅកម្ពុជាផងដែរ។*[27]

### ១.៥.២. ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់គុណភាពរស់នៅ

ជាការពិតណាស់ ភាពក្រីក្រជាកត្តាជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គម ដែលកើតចេញពីកត្តាផ្សេងៗដូចជា ខ្វះការអប់រំ ខ្វះជំនាញ ខ្វះការងារជាដើម។ យោងតាមតថភាពជាក់ស្តែង សហគ្រាសធុនតូច និងមធ្យមមិនតម្រូវឲ្យប្រើប្រាស់កម្លាំងពលកម្មច្រើននោះទេ តែវាជាឱកាសការងារដល់ប្រជាពលរដ្ឋក្នុងតំបន់ផងដែរ។ យោងទៅតាមឯកសារពីធនាគារពិភពលោក បានបង្ហាញថា ខ្លួនបានបញ្ចេញប្រាក់ដ៏ច្រើនរហូតដល់ ១០,០០០លានដុល្លាសហរដ្ឋអាមេរិក ដើម្បីជម្រុញសហគ្រាសធុនតូច និងមធ្យម ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ ដែលនេះអាចឲ្យយើងឃើញថា សហគ្រាសធុនតូច និងមធ្យមមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ។

[27] វិស័យSME មានសរុបប្រមាណជាងប្រាំម៉ឺនកន្លែងនៅកម្ពុជាhttp://kh.cc-times.com/posts/904

# ជំពូកទី២

## ទស្សនទានទូទៅស្តីពីការគ្រប់គ្រងអាជីវកម្មធុនតូច

## «សិប្បកម្មកែច្នៃកំប្លោក»

# ជំពូកទី២

# ទស្សនទាននូវទៅស្តីពីការគ្រប់គ្រងអាជីវកម្មធុនតូច«សិប្បកម្មកែច្នៃកំប្លោក»

## ២.១. ឈ្មោះ ទីតាំង និងភូមិសាស្ត្រនៃតំបន់សិក្សា

### ២.១.១. ឈ្មោះនៃ ខេត្តបាត់ដំបង

បើតាមសិលាចារឹកថ្មប្រាសាទដែលយើងមាន និងបានរកឃើញរហូតសព្វថ្ងៃនៅមុនសម័យ និងសម័យអង្គរគេពុំបានឃើញចែងឲ្យយើងដឹងថា សម័យនោះមានភូមិស្រុកណាមួយដែលមានឈ្មោះបាត់ដំបងនោះទេ។ ប៉ុន្តែយើងក៏មិនហ៊ានសន្និដ្ឋានថា ឈ្មោះបាត់ដំបង នេះមានប្រើ ឬមិនប្រើក្នុងសម័យនោះដែរ។ ប៉ុន្តែក្នុងសម័យអង្គរ និងក្រោយអង្គរ តាមឯកសារមហាជនខ្មែរ មានប្រើឈ្មោះស្រុកបាត់ដំបង។ ហេតុអ្វីបានជាហៅឈ្មោះបាត់ដំបង ប្រវត្តិសាស្ត្រសរសេរលើសិលាចារិកមិនបានឆ្លើយឲ្យដឹងឡើយគឺ មានតែនៅក្នុងរឿងព្រេងប៉ុណ្ណោះគឺរឿងតាដំបងក្រញូង ដែលខ្មែរយើងយល់ថាជារឿងកើតមានតាំងពីសម័យអង្គរដែលបានពន្យល់ពីដើមហេតុដែលនាំឲ្យយើងហៅឈ្មោះ បាត់ដំបង ឬអូរដំបង។

### ២.១.២. ទីតាំង និងភូមិសាស្ត្រនៃខេត្តបាត់ដំបង

ខេត្តបាត់ដំបង ស្ថិតនៅភាគពាយ័ព្យនៃប្រទេសមានចំងាយ ២៩១គីឡូម៉ែត្រពីរាជធានីភ្នំពេញដែលមានព្រំប្រទល់ខាងកើតជាប់ខេត្តពោធិសាត់និងបឹងទន្លេសាប ខាងលិចជាប់ខេត្តប៉ៃលិននិងប្រទេសថៃ ខាងជើងជាប់ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់ខេត្តពោធិ៍សាត់។ ទិសភាគខាងលិចមានព្រំប្រទល់ប្រវែង១៤៨,៨គីឡូម៉ែត្រជាប់ខេត្តច័ន្ទបុរី ត្រាត និងស្រះកែវរបស់ប្រទេសថៃ។ ខេត្តទាំងមូលមានផ្ទៃដីសរុប ១១.៧៤៨គម២ ស្រុកមាន ១៣ និងក្រុង១ ឃុំចំនួន៩២ សង្កាត់១០ និងភូមិចំនួន៨០៩។ ចំនួនគ្រួសារ ២៦៣,៤៣៥គ្រួសារ ប្រជាពលរដ្ឋសរុប ១.២០៥.០៥០នាក់ ស្ត្រីចំនួន ៦០២.៩៩៤នាក់ កម្លាំងពលកម្មជាសក្តានុពលចាប់ពីអាយុ១៨-៣៥ឆ្នាំមានចំនួន៥៦% កំណើនប្រជាពលរដ្ឋប្រចាំឆ្នាំ២.៣% ដង់ស៊ីតេ១០៤.៩២នាក់/គ.ម² ប្រជាពលរដ្ឋប្រកបរបរកសិកម្មចម្បងមាន ៧២,២០% កម្ពស់ទឹកភ្លៀងជាមធ្យម៩៦០.១មម/១ឆ្នាំ អាកាសធាតុ១៣.៥០ºc –៤១.៥០ºc ។ ខេត្តមានច្រកទ្វារព្រំដែនអន្តរជាតិមួយគឺច្រកដូង(ស្រុកកំរៀង) និងច្រកទ្វារតំបន់ព្រំដែន៤ទៀតគឺច្រកទ្វារគីឡូ១៣(ភ្នំដី)ក្នុងស្រុកសំពៅលូន ច្រកទ្វារអូររំដួលក្នុងស្រុកភ្នំព្រឹក ច្រកទ្វារអូរអន្លក់(សួនស៊ុំ)ក្នុងស្រុកកំរៀង និងច្រកទ្វារឆករកា(៤០០)ក្នុងស្រុកសំឡូត។ ស្ថានភាពនៅតាមច្រកព្រំដែនកម្ពុជា-ថៃ គឺមានកិច្ចសហការគ្នាល្អប្រសើរ និងផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមកសម្រួលចរាចរណ៍នាំចេញ-នាំចូល ពិសេសកសិផលប្រជាជននៅស្រុកជាប់ព្រំដែន។ ក្នុងនោះវិស័យទេសចរណ៍ក្នុងខេត្តបាត់ដំបងមានសក្តានុពលខ្ពស់ ដែលបានធ្វើឲ្យប្រជាជនក្នុងតំបន់អាចរកប្រាក់កម្រៃពីវិស័យនេះមកផ្គត់ផ្គង់ជីភាពប្រចាំថ្ងៃ ដោយសារតែនៅក្នុងខេត្តនេះ មានតំបន់ទេសចរណ៍ប្លែកៗជាច្រើន ដែលមានសក្តានុពល និងមានលក្ខណៈពិសេសផ្សេងៗគ្នា រីឯការធ្វើដំណើរទៅកាន់

រមនីយដ្ឋានទេចរណ៍ក៏មានភាពងាយស្រួល ដល់ភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិផងដែរ។ វិស័យទេសចរណ៍ជាវិស័យមួយដែលកំពុងទទួលបានភាពជោគជ័យយ៉ាងខ្លាំងខ្លា ក្នុងការជម្រុញល្បឿននៃការរីកលូតលាស់របស់សេដ្ឋកិច្ចតាមរយៈផលប្រយោជន៍នៃទេសចរណ៍ បន្ទាប់ពីវិស័យកសិកម្ម ។ ប៉ុន្តែដោយសារតែប្រជាជនមួយចំនួនមានការយល់ដឹងពីវិស័យសិប្បកម្ម ពួកគាត់ក៏បានងាកមកចាប់អារម្មណ៍ និងវិស័យសិប្បកម្មហើយវិស័យនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ជីវភាពប្រជាជននៅទីនោះតាមរយៈការផលិត និងកែច្នៃនូវវត្ថុធាតុដើមដែលមានស្រាប់ក្នុងតំបន់ដូចជា សរសៃឈូក ផ្តៅជាដើមឲ្យទៅជារបស់ប្រើប្រាស់ផ្សេងៗ។

តួយ៉ាងក្នុងអំឡុងពេលប្រមាណជា១០ឆ្នាំចុងក្រោយមកនេះប្រជាជនក្នុងខេត្តបាត់ដំបង ដែលស្ថិតនៅក្នុងតំបន់ព្រែកទាល់បានប្រើប្រាស់កំប្លោកមកកែច្នៃធ្វើជា កាបូប កន្ទេល ហិប និង របស់ផ្សេងៗទៀតទៅតាមការកែច្នៃរបស់ប្រើប្រាស់ផ្សេងៗដាក់លក់តាមទីផ្សារជាតិ និងអន្តរជាតិ។ ការខិតខំប្រឹងប្រែងរបស់ពួកគាត់បានជួយសម្រួលដល់ជីវភាពប្រជាជនក្នុងតំបន់បានយ៉ាងច្រើនគួឲ្យកត់សម្គាល់ ដោយស្ត្រីមេផ្ទះក៏អាចរកប្រាក់ចំណូលចូលគ្រួសារបាន និងមនុស្សពេញវ័យក៏អាចធ្វើការងារនេះបានដោយពុំចាំបាច់ធ្វើការចំណាកស្រុកដើម្បីចេញមករកការងារឆ្ងាយពីគ្រួសាររបស់ពួកគេ។




ផែនទី តំបន់សិក្សា

## ២.២. ប្រវត្តិនៃសិប្បកម្មកំប្លោកសហគមន៍សារាយទន្លេ

ក្នុងឆ្នាំ២០០៣ មានជនជាតិបារាំងពីររូបបានធ្វើដំណើរទៅកាន់តំបន់ព្រៃកទាល់នៃខេត្តបាត់ដំបង ហើយបានសិក្សាស្វែងយល់ពីតំបន់នោះដោយបានឃើញពីសក្តានុពលនៃតំបន់ព្រៃកទាល់ ពួកគាត់ទាំងពីរបានសម្រាប់ចិត្តបង្កើតអង្គការមួយដែលមានឈ្មោះថា Osmose នៅកម្ពុជា។បន្ទាប់ពីនោះអ្នកទាំងពីរបានផ្តួចផ្តើមគំនិតបង្កើតនូវសហគមន៍ទេសចរណ៍មួយដែលមានឈ្មោះថា «Saray Tonle (សារាយទន្លេ)» ដែលក្នុងសហគមន៍មានបែងចែកជា៤ផ្នែកធំៗ ដូចជា ផ្ទះស្នាក់ ទូកអុំអាហារដ្ឋាន និងសិប្បកម្មកែច្នៃកំប្លោក។ សហគមន៍នេះបានចូលរួមចំណែកដល់ជីវភាពប្រជាជនឲ្យកាន់តែប្រសើរឡើង ដោយនៅក្នុងគ្រួសារបុរសជាប្តីអាចធ្វើជាអ្នកអុំទូកដឹកភ្ញៀវទេសចរណ៍សម្រាប់ទ្រទ្រង់ជីវភាពក្រៅពីរបរនេសាទ។ ចំណែកឯផ្ទះស្នាក់គឺជាផ្ទះរបស់អ្នករស់នៅក្នុងសហគមន៍ផ្ទាល់ និង អាហារដ្ឋានគឺស្ត្រីនៅក្នុងសហគមន៍រួមគ្នាធ្វើដើម្បីជួយជាកម្លាំងគ្នា។

ក្រៅពីរបរទាំងអស់នេះសហគមន៍ក៏បានបង្កើតនូវសិប្បកម្មកែច្នៃកំប្លោក ដែលបានជួយដល់ជីវភាពរបស់ប្រជាជនដែលរស់ក្នុងសហគមន៍បានមួយកម្រិតទៀត។ មូលហេតុដែលសហគមន៍បង្កើតនូវសិប្បកម្មកែច្នៃកំប្លោកព្រោះតែក្នុងអំឡុងពេល នៃការស្ទង់មតិពីគ្រួសារប្រជាជនក្នុងឆ្នាំ២០០៣ Osmose បានរកឃើញថាមានប្រជាជនខ្លះបានកំពុងតែធ្វើអង្រឹងពីកំប្លោក។ ប៉ុន្តែចំណេះដឹងមូលដ្ឋាននេះក៏មិនត្រូវបានយកទៅអនុវត្តបន្តទៀតនោះទេ ដោយតាមរយៈតម្រូវការទីផ្សារថ្មី នៃទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ គំនិតនៃការបង្កើតឡើងវិញនូវសិល្បៈប្រពៃណីនៃការកែច្នៃកំប្លោកនេះត្រូវបានអនុវត្តឡើងវិញ។ កំប្លោក គឺជារុក្ខជាតិក្នុងទឹកម្យ៉ាងដែលត្រូវបានណែនាំពីអាមេរិកខាងត្បូងដោយវាមានការរាតត្បាត និងចាត់ទុកថាជាគ្រោះមហន្តរាយអេកូឡូស៊ី។ ប៉ុន្តែសហគមន៍បានប្រែក្លាយកំប្លោកពីរបស់គ្រោះថ្នាក់នេះឲ្យទៅជាសេដ្ឋកិច្ចប្រកបដោយចីរភាព។ តាមរយៈការប្រមូលផល សម្ងួត និងកែច្នៃ សិប្បករដែលជាស្ត្រីបានធ្វើពិពិធកម្មផលិតកម្ម និងធ្វើឲ្យវាក្លាយជាកន្ត្រកធម្មជាតិដ៏ស្រស់ស្អាត។ ការលក់របស់ពួកគេនៅលើសាលាបណ្តែតទឹកនៅព្រៃកទាល់ក៏ដូចជាសម្រាប់សណ្ឋាគារ ភោជនីយដ្ឋាន និងការលក់បែបឯកជននៅខេត្តសៀមរាប និងភ្នំពេញ អាចបង្កើតជាប្រាក់ចំណូលយ៉ាងសំខាន់សម្រាប់អ្នកផលិត។ អ្វីដែលសំខាន់ កំប្លោកបានក្លាយជាជម្រើសសេដ្ឋកិច្ចដ៏សំខាន់បំផុតក្នុងការនេសាទ។ បច្ចុប្បន្នផលិតផលដែលកែច្នៃចេញពីកំប្លោកគឺមានភាពពេញនិយមជាខ្លាំងដោយមានការគាំទ្រទាំងក្នុងស្រុក និងក្រៅស្រុក។

## ២.៣. រចនាសម្ព័ន្ធនៃសហគមន៍សិប្បកម្មកែច្នៃកំប្លោកសារាយទន្លេ

### ២.៣.១. រចនាសម្ព័ន្ធនៃសហគមន៍សិប្បកម្មកែច្នៃកំប្លោក

រចនាសម្ព័ន្ធនៃសិប្បកម្មកំប្លោក សហគមន៍សារាយទន្លេ




ប្រភព: អង្គការOsmose

### ២.៣.២. ការចូលរួមរបស់ស្ត្រីក្នុងការងារសហគមន៍

រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកការងារយេនឌ័រជាបញ្ហាសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍ ហើយបានជម្រុញឲ្យមានការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីទាំងឡាយជាបន្តបន្ទាប់។ ក្នុងកិច្ចខិតខំប្រឹងប្រែរបស់រាជរដ្ឋាភិបាលសម្រាប់សេដ្ឋកិច្ចជាតិរយៈពេលជាង២០ឆ្នាំកន្លងមកនេះ បានផ្តល់ឱកាសការងារដល់ស្ត្រីទាំងក្នុងស្រុកនិងក្រៅស្រុក។ ចំពោះអត្រាការចូលរួមកម្លាំងពលកម្មគឺមាន ស្ត្រី៧៧,២% និងបុរស៨៨,៥% ហើយអត្រាអ្នកមានការងារធ្វើ គឺស្ត្រី៤៨,១៩% បុរស៥១,៨១% គិតត្រឹមឆ្នាំ២០១៥។ ប្រាក់កម្រៃដែលទទួលបានពីការងារ គឺជាប្រភពចំណូលមួយភាគធំសម្រាប់ជួយដល់ជីវភាពគ្រួសារ។[28]

ដូចដែលយើងបានដឹងរួចមកហើយ វាពិតជាមានប្រយោជន៍ខ្លាំងណាស់សម្រាប់ស្ត្រី ក្នុងការចូលជាសមាជិកសហគមន៍អាជីវកម្ម ឬបង្កើតសហគមន៍អាជីវកម្មសម្រាប់ស្ត្រី។ នៅប្រទេសកម្ពុជា គេតែងនិយាយថា ស្ត្រីវិលចង្ក្រានមិនជុំ មានន័យថា ស្ត្រីមិនអាចទៅណាឆ្ងាយពីផ្ទះបានឡើយ ព្រោះពួកគេមានតួនាទីមើលថែកូនចៅ និងថែទាំផ្ទះសម្បែង។ ការចូលរួមនៅក្នុងសមាគមន៍អាជីវកម្ម ធ្វើឲ្យស្ត្រីមានលទ្ធភាពក្នុងការជួបប្រជុំ និងបង្កើតទំនាក់ទំនងអាជីវកម្ម ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗបានដូចបុរសដែរ។

[28] ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃទីស្តីការគណៈរដ្ឋមន្ត្រី(http://ocm.gov.kh/ocmwinwin20/wp-content/uploads/2018/11/Gender-Book-of-OCM.pdf)

នៅក្នុងសមាគមន៍អាជីវកម្មមួយ ដែលមានសមាជិកចម្រុះស្ត្រីតែងតែត្រូវគេយោគយល់ និងចាត់ទុកថាជាមនុស្សទន់ខ្សោយជាងបុរស។ នៅក្នុងករណីនេះស្ត្រីភេទកម្រត្រូវបានគេអនុញ្ញាតឲ្យកាន់កាប់មុខសំខាន់ៗណាស់ ព្រោះគេគិតថាការងារខាងក្រៅផ្ទះមិនសាកសមជាមួយស្ត្រីឡើយគឺសម្រាប់តែបុរសប៉ុណ្ណោះ។

ការចូលរួមរបស់ស្ត្រីនៅក្នុងសហគមន៍ គឺផ្តោតសំខាន់ទៅលើការជម្រុញលើកទឹកចិត្តឲ្យស្ត្រីមានភាពក្លាហានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដូចជាដំណើរការអាជីវកម្ម ឬសិប្បកម្មជាដើម។ មានន័យថា ស្ត្រីគួរតែមានពេលវេលាគ្រប់គ្រាន់សម្រាប់ចូលរួមប្រជុំ និងសកម្មភាពផ្សេងទៀតនៅក្នុងសមាគមដើម្បីជួយឲ្យស្ត្រីមានទំនុកចិត្តលើខ្លួនឯងក្នុងការបញ្ចេញមតិក្នុងវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច និងអាចបង្កើតឡើងនូវលក្ខខ័ណ្ឌកាន់តែប្រសើរថែមទៀតសម្រាប់ពួកគេ ដើម្បីទាក់ទាញផលប្រយោជន៍ពេញលេញពីប្រភពធនធាន និងសមត្ថភាពពួកគេ។ ជាក់ស្តែងនៅក្នុងសហគមន៍សារាយទន្លេខេត្តបាត់ដំបងមានសមាជិក ដែលជានាក់តម្បាញកំប្លោកស្ទើរតែ៨០% នៃចំនួនសមាជិកទាំងអស់គឺជាស្ត្រី នេះសបញ្ជាក់ឲ្យឃើញថាស្ត្រីក៏មានសមត្ថភាពក្នុងការដឹកនាំប្រកបបរេ ដើម្បីទ្រទ្រង់ជីវភាពគ្រួសារបានដែរ។

## ២.៤. តួនាទីរបស់ប្រធាន អនុប្រធាននៃសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ

ជាទូទៅគ្រប់ស្ថាប័ន និងក្រុមហ៊ុនទាំងអស់តែងតែមានប្រធាន និងអនុប្រធានដើម្បីដឹកនាំ និងគ្រប់គ្រងឲ្យស្ថាប័នដំណើរទៅប្រកបដោយភាពជោគជ័យ។ តួយ៉ាងនៅក្នុងសហគមន៍សិប្បកម្មកែច្នៃកំប្លោកសារាយទន្លេក៏បានរៀបចំនិងបែងចែកតួនាទីរបស់ប្រធាន និងអនុប្រធានដូចខាងក្រោម៖

### ២.៤.១. តួនាទីរបស់ប្រធានសិប្បកម្មកំប្លោក

- ត្រួតពិនិត្យរបាយការណ៍របស់សមាជិក
- គ្រប់គ្រងចំណូល ចំណាយរបស់សហគមន៍ឲ្យមានភាពយុត្តិធម៌និងច្បាស់លាស់
- អនុវត្តន៍លក្ខន្តិកៈដែលបានចែងរវាងសហគមន៍និងអង្គការអូស្វូស
- ដឹកនាំការងារជារួមរបស់សហគមន៍
- សម្របសម្រួលសមាជិកសិប្បកម្មជាមួយនឹងប្រធានអង្គការអូស្វូស
- រៀបចំផែនការយុទ្ធសាស្ត្រទីផ្សារ
- អនុម័តទៅលើកិច្ចការផ្នែកហិរញ្ញវត្ថុ
- ផ្តល់ការបណ្តុះបណ្តាលដល់សមាជិក
- ដោះស្រាយបញ្ហាចំពោះមុខ
- ស្វែងរកដៃគូសហការ និងរកជំនួយដើម្បីទ្រទ្រង់សហគមន៍
- រៀបចំដឹកនាំដំណើរការប្រព្រឹត្តិទៅរបស់សហគមន៍

- រៀបចំគោលដៅ និងចក្ខុវិស័យរបស់សហគមន៍នាពេលអនាគត

### ២.១.២. តួនាទីរបស់អនុប្រធានសិប្បកម្មកំប្លោក

- សម្របសម្រួលផ្នែកហិរញ្ញវត្ថុនិងការងាររដ្ឋបាល
- កត់ត្រាកិច្ចប្រជុំផ្សេងៗ និងធ្វើរបាយការណ៍ជូនទៅប្រធាន
- គ្រប់គ្រងឯកសារផ្សេងៗរបស់សហគមន៍
- ផ្តល់ព័ត៌មានពីការអភិវឌ្ឍន៍ការងារក្នុងសហគមន៍ទៅកាន់សមាជិកសិប្បកម្ម
- ចូលរួមអនុវត្តន៍ការងារប្រព្រឹត្តិទៅរបស់សហគមន៍
- ជំនួសមុខឲ្យប្រធាននៅពេលអវត្តមាន
- អនុវត្តន៍ភារកិច្ចផ្សេងៗដែលប្រធានដាក់ឲ្យ

### ២.១.៣. ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង

➢ **ភាពជាដឹកនាំ**

ភាពជាដឹកនាំ គឺជាដំណើរការដ៏មានឥទ្ធិពលរបស់ថ្នាក់ដឹកនាំ និងថ្នាក់ក្រោម ដើម្បីឲ្យមានឆន្ទៈធ្វើការឆ្ពោះទៅដល់ការសម្រេចគោលដៅ និងគោលបំណងរបស់អង្គភាពតាមរយៈការផ្លាស់ប្តូរដែលភាសាអង់គ្លេសថា Leadership។ អ្នកដឹកនាំមិនត្រឹមតែមានភាពជាអ្នកដឹកនាំប៉ុណ្ណោះទេ គឺត្រូវមានជំនាញពិសេសៗ សមត្ថភាព និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទើបអាចក្លាយជាអ្នកនាំដ៏ខ្លាំងមួយរូបបាន។[29]

➢ **ការគ្រប់គ្រង**

ការគ្រប់គ្រងគឺជាជាការទទួលខុសត្រូវមួយដ៏លំបាក វាទាមទារឲ្យអ្នកគ្រប់គ្រងចាំបាច់ត្រូវមានសមត្ថភាពយល់ដឹងខ្ពស់រហ័សរហួនប្រកបដោយភាពប៉ុនប្រសព្វ នឹងមានចំណេះដឹងទូលាយបើទោះបីជាយ៉ាងនេះក៏ដោយក៏មានអ្នកគ្រប់គ្រងខ្លះទទួលបានជោគជ័យហើយអ្នកគ្រប់គ្រងបរាជ័យផងដែរ។ ការគ្រប់គ្រងពិតជាសារៈសំខាន់ណាស់ចំពោះការរីកចម្រើនរបស់ក្រុមហ៊ុន ស្ថាប័ន និងសហគមន៍។ សបញ្ជាក់ឲ្យឃើញថាប្រសិនការគ្រប់គ្រងបានល្អនោះការអនុវត្តក្នុងក្រុមហ៊ុន ស្ថាប័ន និងសហគមន៍ក៏ប្រព្រឹត្តិទៅបានរលូន និងរីកចម្រើនផងដែរ។

## ២.៥. វិន័យការងារចំពោះសមាជិកក្នុងសហគមន៍សិប្បកម្មកែច្នៃកំប្លោក

បច្ចុប្បន្ននៅក្នុងសហគមន៍សិប្បកម្មកែច្នៃកំប្លោកសារាយទន្លេមានសមាជិកជាសិប្បករចំនួន ១៤នាក់ ដែលក្នុងនោះមានតែស្ត្រីតែប៉ុណ្ណោះ។ ពេលវេលាធ្វើការរបស់សិប្បករទាំងអស់ក្នុងការតម្បាញកំប្លោកគឺអាស្រ័យទៅលើការកម្ម៉ង់របស់ភ្ញៀវមានន័យថា មិនកំណត់ពេលវេលានោះទេពោល គឺធ្វើយ៉ាងណាឲ្យទទួលបាន

[29] អ្នកដឹកនាំល្អ និពន្ធដោយ អួន ណារ៉ាត ខែតុលា ឆ្នាំ២០១៦

ផលិតផលសម្រេចទៅតាមពេលកំណត់ដែលសហគមន៍ដាក់ជូន។ សហគមន៍ទេសចរណ៍សារាយទន្លេក៏បានចែងជាបទបញ្ញាសម្រាប់ក្រុមសិប្បកម្មកំប្លោកដូចខាងក្រោម ៖

- **ប្រការ១.** គ្រប់សមាជិកសិប្បកម្មកំប្លោកទាំងអស់ត្រូវចូលរួមយាមផែទៅតាមវេនដែលបានបែងចែកនិងសរសេរនៅលើក្ដារខៀនព័ត៌មាននិងចូលរួមប្រជុំពិភាក្សាផ្សេងៗ ដែលបានកំណត់ដោយអ្នកសម្របសម្រួលសហគមន៍ទេសចរណ៍ សារាយទន្លេ។
- **ប្រការ២.** គ្រប់សមាជិកសិប្បកម្មកំប្លោកទាំងអស់ត្រូវបានចូលរួមវគ្គបណ្ដុះបណ្ដាលបន្ថែមលើជំនាញថ្មីៗ និងធ្វើជាគ្រូបណ្ដុះបណ្ដាលសម្រាប់ក្រុមសមាជិកចូលថ្មី។
- **ប្រការ៣.** សមាជិកសិប្បកម្មកំប្លោក និងក្រុមគ្រួសារទាំងអស់មិនអនុញ្ញាតឲ្យទទួលកម្ម៉ង់ពីអតិថិជនណាផ្សេងក្រៅពីតាមរយៈសហគមន៍ទេសចរណ៍សារាយទន្លេ ក្រោមការជួយជ្រោមជ្រែងរបស់អង្គការអូស្មូសឡើយ។
- **ប្រការ៤.** សមាជិកសិប្បកម្មកំប្លោក និងក្រុមគ្រួសារទាំងអស់ត្រូវចូលរួមសហការក្នុងការផ្ដល់ព័ត៌មាននានាពាក់ព័ន្ធ និងសមាជិកក្រុមគ្រួសារដែលទទួលធ្វើកម្ម៉ង់ឲ្យអតិថិជនឬក្រុមហ៊ុនណាផ្សេងក្រៅពីសហគមន៍ទេសចរណ៍សារាយទន្លេ។
- **ប្រការ៥.** ត្រូវធានាឲ្យបាននូវការទទួលធ្វើផលិតផលកម្ម៉ង់ឲ្យបានតាមការកំណត់របស់អ្នកសម្របសម្រួលសហគមន៍ទេសចរណ៍ សារាយទន្លេ។
- **ប្រការ៦.** ក្នុងករណីអ្នកតម្បាញមានធុរៈចាំបាច់ ឬមានជម្ងឺធ្ងន់ធ្ងរមិនអាចផ្គត់ផ្គង់ផលិតផលកម្ម៉ង់តាមការកំណត់បាន ត្រូវផ្ដល់ព័ត៌មានមកអ្នកសម្របសម្រួលសហគមន៍ឲ្យបានយ៉ាងតិចមួយសប្ដាហ៍ដើម្បីប្ដូរទៅឲ្យអ្នកផ្សេងធ្វើជំនួសវិញ។ ប្រសិនបើអ្នកទទួលកម្ម៉ង់មិនបានផ្ដល់ព័ត៌មានដល់ទៅអ្នកសម្របសម្រួលនោះទេ នោះរាល់ការខូចខាតទាំងអស់ដែលកើតមានឡើងពីការធ្វើមិនទាន់ពេលកំណត់ ម្ចាស់សាម៉ីខ្លួនគឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើវគ្គកម្ម៉ង់នីមួយៗ។
- **ប្រការ៧.** សម្រាប់ការទទួលធ្វើកម្ម៉ង់ថ្មី សាម៉ីខ្លួនត្រូវតែមកទទួលផ្ទាល់មិនអាចផ្ដល់ឲ្យតាមរយៈផ្ញើ និងក្រុមគ្រួសារឬមិត្តភ័ក្ត្រឡើយ។
- **ប្រការ៨.** មិនអនុញ្ញាតឲ្យទុកដាក់សំភារៈនិងគ្រឿងធ្វើម្ហូបនៅលើផែជាប្រចាំថ្ងៃឡើយ ជាពិសេសហាមមិនឲ្យហូបចុកគ្រឿងស្រវឹងព្រោះអាចធ្វើឲ្យមានក្លិនមិនល្អសម្រាប់ភ្ញៀវទេសចរដែលចូលមកទស្សនានៅលើផែ។

- **ប្រការ៩.** គ្រប់សមាជិកសិប្បកម្មកំប្លោក និងក្រុមគ្រួសារទាំងអស់ត្រូវរក្សាភាពស្ងៀមស្ងាត់ និងមិនត្រូវបង្កជម្លោះផ្សេងៗរវាងសមាជិកក្នុងក្រុមលើផែសិប្បកម្មឡើយព្រោះអាចប៉ះពាល់ដល់កិត្តិយសសហគមន៍ និងភ្ញៀវទេសចរដែលមកកំសាន្តនៅលើផែសិប្បកម្ម។
- **ប្រការ១០.** គ្រប់សមាជិកសិប្បកម្មកំប្លោក និងក្រុមគ្រួសារទាំងអស់ដែលបានអនុវត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងខាងលើនឹងត្រូវទទួលបានការណែនាំ និងព្រមានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរច្រើនបំផុតចំនួនពីរដង ឬក៏ត្រូវបានបញ្ឈប់ភ្លាមៗ ពីសមាជិកសហគមន៍ទេសចរណ៍សារាយទន្លេក្នុងករណីដែលមិនអាចលើកលែងបានតាមការសម្រេចរបស់អ្នកសម្របសម្រួល បន្ទាប់ពីមានការប្រឹក្សាយោបល់ពីតំណាងអង្គការOsmose(អូស្មូស)។

## ២.៦. ដំណើរការការងារនៃសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ

កំប្លោកគឺជារុក្ខជាតិមួយដែលមានអត្ថប្រយោជន៍ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងច្រើនយ៉ាង ដូចជាផ្កាកំប្លោកយើងអាចយកមកធ្វើជាម្ហូបអាហារដូចជា អន្លក់ទឹកគ្រឿង បន្លែនំបញ្ចុកជាដើម ហើយម្យ៉ាងវិញទៀតដោយយោងទៅតាមគេហទំព័រមួយបានផ្សាយថា កំប្លោកអាចកែច្នៃទៅជាជីកំប៉ុសដែលមានគុណភាពល្អព្រោះរុក្ខជាតិនេះអាចរលួយបានលឿន ចំណេញវេលា និងថវិការផងដែរ។ បន្ថែមពីនេះទៅទៀតក៏អាចយកមកកែច្នៃទៅ ជារបស់របរប្រើប្រាស់ប្រចាំថ្ងៃជាច្រើនយ៉ាងដូចជា កាបូប កន្ទេល កម្រាលព្រំ ថូរផ្កា អង្រឹង មួក កន្ត្រក់ ប្រអប់ដាក់ក្រដាសជូតមាត់ ជាដើម។



ប្រភព: osmosetonlesap.net

ជាការពិតណាស់ការប្រកបរបរតម្បាញកំប្លោកជាមុខរបរមួយ ដែលមានលក្ខណៈស្មុគស្មាញនិងច្រើនដំណាក់កាលដែលតម្រូវឲ្យយើងយកចិត្តទុកដាក់ និងចំណាយពេលវេលាច្រើនយ៉ាងតិច២សប្តាហ៍ក្នុងការតម្បាញឲ្យចេញជាផលិតផលសម្រេចមួយលក់ទៅកាន់អតិថិជន។ ដំណើរការក្នុងការតម្បាញកំប្លោកគេត្រូវតម្បាញដោយផ្ទាល់ដៃដើម្បីទទួលបានក្រឡាញឹក និងផ្ទៃស្អាតល្អ។ ដំណាក់កាលដំបូងបង្អស់នៃការតម្បាញនោះសមាជិកត្រូវទៅទន្លេដើម្បីជ្រើសរើសយកកំប្លោកដែលល្អៗ ហើយយកកំប្លោកមកលាងសម្អាតជាមួយសាប៊ូឲ្យជ្រះភក់អស់ដំណាក់កាលទីពីរយើងត្រូវយកកំប្លោកដែលលាងជម្រះឲ្យស្អាតរួចយកមកហាលឲ្យស្ងួតប្រហែលជា១៤ថ្ងៃ បន្ទាប់មកដំណាក់កាលទីបីបន្ទាប់ពីកំប្លោកស្ងួតល្អហើយយើងត្រូវយកកំប្លោកមកស្ដុងជាមួយស្ពាន់ធ័ររយៈពេល៤៥នាទីដើម្បីកុំឲ្យមានសត្វល្អិតស៊ីកំប្លោក និងឡើងអុចខ្មៅ បន្ទាប់មកទៀតត្រូវយកមកហាលថ្ងៃឲ្យស្ងួតម្ដងទៀតនិងចុងក្រោយដំណាក់កាលទីបួន បន្ទាប់ពីទទួលបានកំប្លោកស្ងួតល្អពីការសម្ងួតលើកទីពីរហើយនោះទើបអាចយកមកតម្បាញជាផលិតផលសម្រេចបាន។



*ដំណាក់កាលទី១*



*ដំណាក់កាលទី៣*



*ដំណាក់កាលទី២*



*ដំណាក់កាលទី៤*

ប្រភព: osmosetonlesap.net

សិប្បករម្នាក់ៗអាចមានសមត្ថភាពក្នុងការតម្បាញកំប្លោកឲ្យចេញជាលទ្ធផលសម្រេចពីចន្លោះពី១០ទៅ១៥ផលិតផលក្នុងមួយខែអាស្រ័យទៅតាមទំហំ និងម៉ូតរបស់អតិថិជនធ្វើការបញ្ជាទិញ។ ផលិតផលរបស់សហគមន៍សារាយទន្លេមានគុណភាពល្អប្រើប្រាស់បានរហូតទៅដល់៣ឆ្នាំឬលើសពីនេះទៅតាមការថែទាំរបស់អ្នកប្រើប្រាស់ហើយក៏ទទួលបានទំនុកចិត្តពីអតិថិជនទាំងក្រៅស្រុក និងក្នុងស្រុកផងដែរ។ ប្រទេសដែលបាននាំចូលផលិតផលខាងសហគមន៍មានដូចជា ប្រទេសកូរ៉េ អូស្ត្រាលី អាមេរិច និងអង់គ្លេស គ្រប់ផលិតផលទាំងអស់ទទួលបានការគាំទ្រ និងពេញចិត្តយ៉ាងខ្លាំងទៅលើគុណភាព និងតម្លៃពីសំណាក់អតិថិជន ព្រោះតម្លៃដែល

សហគមន៍លក់ចេញមានភាពសមរម្យដោយក្នុងមួយផលិតផលមានតម្លៃចាប់ពី៥$ទៅ២០$ ហើយផលិតផលដែលមានការពេញនិយម និងទទួលបានការបញ្ជាទិញច្រើនជាងគេគឺកាបូបដែលមានការរចនាម៉ូតចេញពីគ្រូដែលមានជំនាញ។ តាមរយៈកិច្ចសំភាសន៍ជាមួយប្រធានសហគមន៍សារាយទន្លេបានឲ្យដឹងថា *«មធ្យោបាយក្នុងការលក់ផលិតផលចេញរបស់ពួកគាត់ធ្វើឡើងតាមរយៈការដាក់តាំងផលិតផលលក់នៅលើផែនៃភូមិព្រែកទាល់, តាមរយៈវេបសាយរបស់សហគមន៍សារាយទន្លេ និងតាមរយៈអ្នកមគ្គុទេសទេសចរណ៍។ លើសពីនេះទៅទៀតផលិតផលរបស់ពួកគាត់ក៏ធ្លាប់បានចូលរួមក្នុងការតាំងពិពណ៌របស់កម្មវិធី Friend beach និង Friend volunteer ហើយពួកគាត់ក៏ត្រូវបានទូរទស្សន៍បារាំងចុះមកសំភាសន៍អំពីដំណើរការក្នុងការកែច្នៃកំប្លោកកាលឆ្នាំ២០១៨កន្លងទៅ»*។ គ្រប់មធ្យោបាយទាំងនេះហើយជាវិធីសាស្រ្តក្នុងការស្វែងរកទីផ្សាររបស់សហគមន៍សារាយទន្លេក្នុងការលក់ចេញផលិតដែលកែច្នៃមកពីរុក្ខជាតិទឹកមួយប្រភេទនេះ។

### ២.៦.១. ដំណើរការការងារមុនពេលមានការរីករាលត្បាតនៃជំងឺកូវីដ១៩

ដោយយោងទៅតាមការដកស្រង់ទិន្នន័យពីប្រធានសហគមន៍បានឲ្យដឹងថាដំណើរការនៃការប្រព្រឹត្តិទៅរបស់សិប្បកម្មកំប្លោកមុនកើតមានជំងឺកូវីដ១៩ គឺពិតជាល្អប្រសើរខ្លាំងនិងទទួលបានការបញ្ជាទិញច្រើនមិនថាទាំងក្នុងស្រុក និងក្រៅស្រុកដែលធ្វើឲ្យសហគមន៍ទទួលបានប្រាក់ចំណូលសមរម្យពីមួយខែទៅមួយខែដើម្បីទ្រទ្រង់សហគមន៍ និងជីវភាពរបស់សិប្បករក្នុងសហគមន៍។ លើសពីនេះទៅទៀតលោកក៏បានបញ្ជាក់ទៀតថាក្នុងឆ្នាំ២០១៨ខាងសិប្បកម្មរបស់គាត់លក់បានផលិតផលពីចន្លោះ២០០ ទៅ ៣០០ផលិតផលក្នុងមួយខែ។ ក្នុងអំឡុងពេលនោះភ្ញៀវទេសចរណ៍បានមកកំសាន្តនៅក្នុងសហគមន៍របស់គាត់ច្រើនគួរឲ្យកត់សម្គាល់ ដែលអត្រានៃការលក់មានការកើនឡើងជាលំដាប់។ ក្រៅពីការទទួលបានប្រាក់ចំណូលពីការលក់ផលិតផលនៅផែ និងការបញ្ជាទិញតាមរយៈប្រព័ន្ធវេបសាយ ហើយនោះខាងសហគមន៍ក៏បានរៀបចំបើកជាថ្នាក់បង្រៀនសម្រាប់ភ្ញៀវទេសចរណ៍ដែលមានចំណាប់អារម្មណ៍ទៅលើការតម្បាញកំប្លោកដើម្បីជាចំណូលបន្ថែមទៅដល់សហគមន៍។

### ២.៦.២. ដំណើរការការងារអំឡុងពេលមានការរីករាលត្បាតនៃជំងឺកូវីដ១៩

បច្ចុប្បន្នពិភពលោកកំពុងតែប្រឈមនឹងការរីករាលត្បាតនៃជំងឺកូវីដ១៩ ដែលធ្វើឲ្យសេដ្ឋកិច្ចពិភពលោកមានការធ្លាក់ចុះយ៉ាងគំហុក ហើយប្រទេសខ្លះឈានទៅដល់ការបិទប្រទេសទាំងស្រុងថែមទៀតផង។ ការបិទប្រទេសមានផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ វិស័យអប់រំជាដើម។ ក៏ដូចគ្នានេះដែរការរីករាលត្បាតនៃជំងឺនេះ ក៏បានជះឥទ្ធិពលដល់ប្រទេសកម្ពុជាឲ្យទទួលរងនូវផលប៉ះពាល់ដល់គ្រប់វិស័យទាំងអស់ដូចជា វិស័យសេដ្ឋកិច្ច វិស័យអប់រំ វិស័យសុខាភិបាល វិស័យទេសចរណ៍ វិស័យសិប្បកម្មនិងឧស្សាហកម្មទៀតផង។ ជាក់ស្តែងសហគមន៍សិប្បកម្មកែច្នៃកំប្លោកក៏កំពុងតែជួបប្រទះនូវវិបត្តិយ៉ាងធ្ងន់ធ្ងរពីបញ្ហានេះដូចគ្នា។ ខាងក្រោមនេះជាបញ្ហាមួយចំនួនធំដែលសហគមន៍សិប្បកម្មកំប្លោកកំពុងតែជួបប្រទះ៖

- បាត់បង់ប្រភពនៃប្រាក់ចំណូលយ៉ាងខ្លាំងដែលបានមកការបញ្ជាទិញពីភ្ញៀវជាតិនិងអន្តរជាតិ។

- បាត់បង់ធនធានមនុស្សព្រោះសិប្បករមួយចំនួនដាក់ពាក្យលាឈប់
- បាត់បង់ភ្ញៀវទេសចរណ៍ទាំងជាតិ និងភ្ញៀវអន្តរជាតិមកកំសាន្តក្នុងតំបន់សហគមន៍ព្រែកទាល់ស្ទើរតែទាំងស្រុង
- សិប្បករដែលនៅសល់កំពុងជួបប្រទះនឹងការខ្វះខាតផ្នែកហិរញ្ញវត្ថុ
- ប្រជាជននៅក្នុងសហគមន៍ត្រូវធ្វើចំណាកស្រុកដើម្បីរកប្រាក់ចំណូលបន្ថែម។

## ២.៧. ការគ្រប់គ្រងហិរញ្ញវត្ថុក្នុងសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ

### ២.៧.១. សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ

ជាទូទៅរបាយការណ៍ហិរញ្ញវត្ថុរបស់សហគមន៍សារាយទន្លេគឺតម្រូវឲ្យរៀបចំទៅតាមការកំណត់របស់អង្គការ Osmose(អូស្មូស)។ ការដែលមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដ៏ល្អមួយមានសារៈសំខាន់ណាស់សម្រាប់អាជីវកម្មសមាគមន៍សារាយទន្លេ។ សហគមន៍បានផ្តល់ព័ត៌មានយ៉ាងច្បាស់ដល់សមាជិករបស់ខ្លួនអំពីការចំណាយផ្សេងៗដែលកើតមានឡើង និងថវិកាចំណូលផ្សេងៗ។ សម្រាប់វិធីសាស្ត្រកត់ត្រា មានភាពសាមញ្ញ ប៉ុន្តែមានប្រសិទ្ធិភាព។ ប្រសិនបើគ្មានប្រព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវនោះទេ នោះប្រព័ន្ធនៃការគ្រប់គ្រងចំណូលចំណាយច្បាស់ជាមានបញ្ហា ដែលអាចធ្វើឲ្យមានឱនភាពរបស់សហគមន៍ មានការមិនចុះសម្រុង ឬ មិនទុកចិត្តគ្នា ជុំវិញបញ្ហាហិរញ្ញវត្ថុសមាគមន៍សារាយទន្លេ។ សហគមន៍បានផ្តល់ព័ត៌មានយ៉ាងច្បាស់ដល់សមាជិករបស់ខ្លួន អំពីការចំណាយផ្សេងៗ ដែលកើតមានឡើង និងថវិកាចំណូលផ្សេងៗ។

### ២.៧.២.. ផែនការថវិកា

ផែនការថវិកាគឺជាផែនការហិរញ្ញវត្ថុ ដែលបង្ហាញនូវការសង្ឃឹមទុករបស់សហគមន៍សារាយទន្លេ ពីចំណូល និងចំណាយសម្រាប់រយៈពេលមួយជាទូទៅគឺសម្រាប់មួយឆ្នាំ។ វាឆ្លុះបញ្ចាំងពីផែនការសកម្មភាព រួមទាំងគម្រោងចំណាយ និងការប៉ាន់ប្រមាណអំពីថវិកាចំណូល ដែលរំពឹងទុកផ្អែកតាមចំណូលពីមុននិងចំណូលព្យាករណ៍ពីសកម្មភាពថ្មីៗ។ ជាទូទៅសហគមន៍គឺអាចទទួលបានចំណូលមួយដែលមានតុល្យភាពពេលគឺនៅពេលចំនាយ និងចំណូលមានកម្រិតប្រហាក់ប្រហែលគ្នា ដូច្នេះសហគមន៍អាចមានថវិកាចំណូលគ្រប់គ្រាន់សម្រាប់ចំណាយ ដូចដែលបានរំពឹងទុក។ ប៉ុន្តែក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ(២០២០-២០២១) ថវិកាចំណូលរបស់សហគមន៍មានការថយចុះគួរឲ្យកត់សម្គាល់បណ្តាលមកពីបញ្ហាជំងឺឆ្លងកូវីដ១៩ ដែលធ្វើឲ្យការបញ្ញាទិញមានការថយចុះជាលំដាប់។

ខាងក្រោមជាតារាងចំណូលចំណាយរបស់សហគមន៍ក្នុងរយៈពេល៦ឆ្នាំ ចាប់ពីឆ្នាំ២០១៦-២០២១

- ឆ្នាំ២០១៦

| SARAY CBET - គម្រោងចំណូលចំនាយឆ្នាំ 2016 | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សិប្បកម្មកំប្លោក | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | ថវិកាសរុបប្រចាំឆ្នាំ |
| ចំណូល | | | | | | | | | | | | | |
| ការលក់នៅលើផែ | $ 91.00 | $ 378.68 | $ 433.86 | $ 877.76 | $ - | $ 850.00 | $ 779.00 | $ 890.00 | $ 200.00 | $ 500.00 | $ 870.00 | $ 764.89 | $ 6,635.19 |
| ការលក់តាមការបញ្ជាទិញ | $ 400.87 | $ - | $ 537.98 | $ 365.00 | $ 300.54 | $ 230.87 | $ 1,200.00 | $ 980.33 | $ 830.88 | $ 1,000.00 | $ 1,615.00 | $ 950.00 | $ 8,411.47 |
| ការបង្រៀនភ្ញៀវទេសចរណ៍ | $ 73.00 | $ 100.00 | $ 123.00 | $ 100.00 | $ 30.00 | $ 150.00 | $ 155.00 | $ 100.00 | $ 18.00 | $ 111.00 | $ 98.00 | $ 125.00 | $ 1,183.00 |
| ថវិកាសរុប | **$ 564.87** | **$ 478.68** | **$ 1,094.84** | **$ 1,342.76** | **$ 330.54** | **$ 1,230.87** | **$ 2,134.00** | **$ 1,970.33** | **$ 1,048.88** | **$ 1,611.00** | **$ 2,583.00** | **$ 1,839.89** | $ 16,229.66 |
| ចំណាយ | | | | | | | | | | | | | |
| សំរាប់កម្លាំងពលកម្មស្ត្រី | $ 327.56 | $ 197.10 | $ 650.98 | $ 790.00 | $ 127.87 | $ 905.05 | $ 1,870.00 | $ 1,689.00 | $ 700.58 | $ 1,400.00 | $ 2,215.00 | $ 1,637.33 | $ 14,900.49 |
| ថវិកាសារាបប្រែប្រាសក្នុងសហគមន | $ 237.31 | $ 281.58 | $ 443.86 | $ 552.76 | $ 202.67 | $ 325.82 | $ 264.00 | $ 281.33 | $ 348.30 | $ 211.00 | $ 368.00 | $ 202.56 | $ 8,239.80 |
| ចំនាយក្នុងសហគមន៏ | $ 200.97 | $ - | $ 500.00 | $ 455.23 | $ 102.45 | $ 822.76 | $ 95.23 | $ 204.89 | $ 384.34 | $ - | $ 250.00 | $ 180.76 | $ 3,196.63 |
| ថវិកាដែលនៅសល់ | **$ 36.34** | **$ 281.58** | **$ (56.14)** | **$ 97.53** | **$ 100.22** | **$ (496.94)** | **$ 168.77** | **$ 76.44** | **$ (36.04)** | **$ 211.00** | **$ 118.00** | **$ 21.80** | $ 522.56 |

- ឆ្នាំ២០១៧

| SARAY CBET - គម្រោងចំណូលចំនាយឆ្នាំ 2017 | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សិប្បកម្មកំប្លោក | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | ថវិកាសរុបប្រចាំឆ្នាំ |
| ចំណូល | | | | | | | | | | | | | |
| ការលក់នៅលើផែ | $ 1,020.00 | $ 1,000.00 | $ 562.00 | $ 233.00 | $ 100.00 | $ 91.00 | $ 150.00 | $ 320.87 | $ 200.00 | $ 460.00 | $ 1,615.00 | $ 1,137.27 | $ 6,889.14 |
| ការលក់តាមការបញ្ជាទិញ | $ 330.00 | $ 250.00 | $ 2,438.45 | $ - | $ 621.21 | $ 1,502.56 | $ 200.00 | $ 980.33 | $ 830.88 | $ 1,600.00 | $ 856.54 | $ 587.00 | $ 10,196.97 |
| ការបង្រៀនភ្ញៀវទេសចរណ៍ | $ 200.00 | $ 365.00 | $ 200.00 | $ 120.00 | $ 55.00 | $ 73.00 | $ 155.00 | $ 190.00 | $ 18.00 | $ 111.00 | $ 98.00 | $ 87.00 | $ 1,672.00 |
| ថវិកាសរុប | **$ 1,550.00** | **$ 1,615.00** | **$ 3,200.45** | **$ 353.00** | **$ 776.21** | **$ 1,666.56** | **$ 505.00** | **$ 1,491.20** | **$ 1,048.88** | **$ 2,171.00** | **$ 2,569.54** | **$ 1,811.27** | $ 18,758.11 |
| ចំណាយ | | | | | | | | | | | | | |
| សំរាប់កម្លាំងពលកម្មស្ត្រី | $ 810.10 | $ 902.00 | $ 2,000.00 | $ 197.10 | $ 533.82 | $ 905.05 | $ 320.00 | $ 820.00 | $ 700.58 | $ 1,400.00 | $ 2,198.00 | $ 1,458.00 | $ 14,900.49 |
| ថវិកាសំរាប់ប្រើប្រាស់ក្នុងសហគមន៏ | $ 739.90 | $ 713.00 | $ 1,200.45 | $ 155.90 | $ 242.39 | $ 761.51 | $ 185.00 | $ 671.20 | $ 348.30 | $ 771.00 | $ 371.54 | $ 353.27 | $ 8,239.80 |
| ចំនាយក្នុងសហគមន៏ | $ 261.00 | $ 455.23 | $ 500.00 | $ - | $ 102.45 | $ 822.76 | $ 95.23 | $ 498.10 | $ 384.34 | $ 418.40 | $ 570.56 | $ 618.26 | $ 4,726.33 |
| ថវិកាដែលនៅសល់ | **$ 478.90** | **$ 257.77** | **$ 700.45** | **$ 155.90** | **$ 139.94** | **$ (61.25)** | **$ 89.77** | **$ 173.10** | **$ (36.04)** | **$ 352.60** | **$ (199.02)** | **$ (264.99)** | $ 1,787.13 |

- ឆ្នាំ២០១៨

| SARAY CBET - គម្រោងចំណូលចំនាយឆ្នាំ 2018 | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សិប្បកម្មកំប្លោក | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | ថវិកាសរុបប្រចាំឆ្នាំ |
| ចំណូល | | | | | | | | | | | | | |
| ការលក់នៅលើផែ | $ 1,463.00 | $ 1,277.00 | $ 562.00 | $ 233.00 | $ 86.00 | $ 91.00 | $ 206.00 | $ 522.00 | $ 221.00 | $ 460.00 | $1,615.00 | $1,147.00 | **$ 7,883.00** |
| ការលក់តាមការបញ្ជាទិញ | $ 560.80 | $ 455.95 | $ 2,438.45 | $ - | $ 899.20 | $2,059.50 | $ 33.00 | $1,362.55 | $ 933.10 | $1,788.24 | $ 789.70 | $ 597.00 | **$ 11,917.49** |
| ការបង្រៀនភ្ញៀវទេសចរណ៍ | $ 294.00 | $ 395.00 | $ 255.00 | $ 120.00 | $ 68.00 | $ 73.00 | $ 456.00 | $ 324.00 | $ 18.00 | $ 111.00 | $ 705.00 | $ 522.00 | **$ 3,341.00** |
| **ថវិកាសរុប** | **$ 2,317.80** | **$ 2,127.95** | **$ 3,255.45** | **$ 353.00** | **$1,053.20** | **$2,223.50** | **$ 695.00** | **$2,208.55** | **$1,172.10** | **$2,359.24** | **$3,109.70** | **$2,266.00** | $ 23,141.49 |
| ចំណាយ | | | | | | | | | | | | | |
| សំរាប់កម្លាំងពលកម្មស្ត្រី | $ 1,541.08 | $ 1,372.47 | $ 2,000.97 | $ 197.10 | $ 533.82 | $1,349.40 | $ 526.50 | $1,405.93 | $ 729.56 | $1,455.94 | $2,191.82 | $1,595.90 | **$ 14,900.49** |
| ថវិកាសំរាប់ប្រើប្រាស់ក្នុងសហគមន៍ | $ 776.72 | $ 755.48 | $ 1,254.48 | $ 154.50 | $ 519.38 | $ 874.10 | $ 168.50 | $ 802.62 | $ 442.54 | $ 903.30 | $ 917.88 | $ 670.00 | **$ 8,239.80** |
| ចំនាយក្នុងសហគមន៍ | $ 262.69 | $ 455.23 | $ 455.23 | $ 214.26 | $ 410.98 | $ 822.76 | $ 228.18 | $ 438.36 | $ 384.34 | $ 418.40 | $ 570.56 | $ 618.26 | **$ 5,279.25** |
| **ថវិកាដែលនៅសល់** | **$ 514.03** | **$ 300.25** | **$ 799.25** | **$ (59.76)** | **$ 108.41** | **$ 51.34** | **$ (59.68)** | **$ 364.26** | **$ 58.20** | **$ 484.90** | **$ 347.32** | **$ 51.74** | $ 2,960.25 |

- ឆ្នាំ២០១៩

SARAY CBET - គម្រោងចំណូលចំនាយឆ្នាំ 2019

| សិប្បកម្មកំប្លោក | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | ថវិកាសរុបប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល | | | | | | | | | | | | | |
| ការលក់នៅលើផែ | $ 1,083.00 | $ 1,047.00 | $ 563.00 | $ 453.48 | $ 84.00 | $ 81.00 | $ 391.00 | $ 408.00 | $ 465.00 | $3,320.30 | $ 5,204.00 | $1,101.00 | $ 14,200.78 |
| ការលក់តាមការបញ្ជាទិញ | $ 120.00 | $ 810.74 | $ - | $2,594.63 | $ 26.00 | $1,458.70 | $ 701.70 | $ 632.30 | $ 653.00 | $1,002.50 | $ 1,473.00 | $ 143.00 | $ 9,615.57 |
| ការបង្រៀនភ្ញៀវទេសចរណ៍ | $ 270.00 | $ 306.00 | $ 252.00 | $ 63.00 | $ 36.00 | $ 120.00 | $ 285.00 | $ 327.00 | $ 39.00 | $ 162.00 | $ 303.00 | $ 528.00 | $ 2,691.00 |
| ចំណូលពីភ្ញៀវទេសចរណ៍ដែលមកតាមរយៈអង្គការOsmose | $ - | $ 739.00 | $ 509.00 | $ 97.00 | $ 83.00 | $ 76.00 | $ 354.00 | $ 525.00 | $ 39.00 | $ 378.00 | $ 315.00 | $ 681.00 | $ 3,796.00 |
| ចំណូលពីភ្ញៀវទេសចរណ៍ដែលមកតាមរយៈGuide | $ - | $ 614.00 | $ 306.00 | $ 419.48 | $ 37.00 | $ 125.00 | $ 322.00 | $ 210.00 | $ 465.00 | $3,104.30 | $ 5,192.00 | $ 948.00 | $ 11,742.78 |
| **ថវិកាសរុប** | **$ 1,473.00** | **$ 3,516.74** | **$ 1,630.00** | **$3,627.59** | **$ 266.00** | **$1,860.70** | **$2,053.70** | **$2,102.30** | **$1,661.00** | **$7,967.10** | **$ 12,487.00** | **$3,401.00** | $ 42,046.13 |
| ចំណាយ | | | | | | | | | | | | | |
| សំរាប់កម្លាំងពលកម្មស្រ្តី | $ 932.00 | $ 687.40 | $ 604.10 | $1,710.78 | $ 104.40 | $1,031.92 | $ 932.22 | $ 937.48 | $ 749.80 | $ 718.50 | $ 4,379.20 | $1,266.20 | $ 14,045.60 |
| ថវិកាសំរាប់ប្រើប្រាស់ក្នុងសហគមន៍ | $ 540.40 | $ 863.70 | $ 210.90 | $1,400.33 | $ 41.60 | $ 627.78 | $ 445.48 | $ 429.82 | $ 407.20 | $1,719.52 | $ 2,600.80 | $ 505.80 | $ 9,793.33 |
| ចំនាយក្នុងសហគមន៍ | $ 93.38 | $ 646.55 | $ 188.38 | $ 284.35 | $ 44.98 | $ 195.55 | $ 150.67 | $ 472.31 | $ 126.18 | $ 313.63 | $ 378.08 | $ 309.56 | $ 3,203.62 |
| **ថវិកាដែលនៅសល់** | **$ 447.02** | **$ 217.15** | **$ 22.52** | **$1,115.98** | **$ (3.38)** | **$ 432.23** | **$ 294.81** | **$ (42.49)** | **$ 281.02** | **$1,405.89** | **$ 2,222.72** | **$ 196.24** | $ 6,589.71 |

- ឆ្នាំ២០២០

SARAY CBET - គម្រោងចំណូលចំនាយឆ្នាំ 2020

| សិប្បកម្មកំប្លោក | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | ថវិកាសរុបប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល | | | | | | | | | | | | | |
| ការលក់នៅលើផែ | $ 6,083.00 | $ 2,102.00 | $ 2,667.00 | $ - | $ 107.00 | $ 412.00 | $ 714.00 | $ 756.00 | $ 851.00 | $ 554.00 | $ 617.00 | $ 415.00 | $ 15,278.00 |
| ការលក់តាមការបញ្ជាទិញ | $ 1,033.41 | $ 419.50 | $ 77.10 | | $ 110.10 | | $ 15.00 | $ 612.00 | $ 144.40 | $ - | $ 723.45 | $ 459.35 | $ 3,594.31 |
| ការបង្រៀនភ្ញៀវទេសចរណ៍ | $ 438.00 | $ 360.00 | $ 120.00 | | | | | | | $ - | | $ 15.00 | $ 933.00 |
| ចំណូលពីភ្ញៀវទេសចរណ៍ដែលមកតាមរយៈអង្គការOsmose | $ 696.00 | $ 469.00 | $ 125.00 | | | | | | | | | | $ 1,290.00 |
| ចំណូលពីភ្ញៀវទេសចរណ៍ដែលមកតាមរយៈGuide | $ 5,825.00 | $ 1,993.00 | $ 2,662.00 | $ 99.00 | $ 107.00 | $ 412.00 | $ 714.00 | $ 756.00 | $ 851.00 | $ 554.00 | $ 617.00 | $ 430.00 | $ 15,020.00 |
| **ថវិកាសរុប** | **$14,075.41** | **$ 5,343.50** | **$ 5,651.10** | **$ 99.00** | **$ 324.10** | **$ 824.00** | **$ 1,443.00** | **$ 2,124.00** | **$ 1,846.40** | **$ 1,108.00** | **$ 1,957.45** | **$ 1,319.35** | $ 36,115.31 |
| ចំណាយ | | | | | | | | | | | | | |
| សំរាប់កម្លាំងពលកម្មស្រ្តី | $ 4,716.95 | $ 1,295.80 | $ 1,763.11 | $ 59.40 | $ 130.26 | $ 247.20 | $ 437.40 | $ 820.80 | $ 597.24 | $ 332.40 | $ 804.27 | $ 536.61 | $ 11,741.44 |
| ថវិកាសំរាប់ប្រើប្រាស់ក្នុងសហគមន៍ | $ 2,837.96 | $ 1,377.10 | $ 1,100.90 | $ 39.60 | $ 86.84 | $ 164.80 | $ 291.60 | $ 547.20 | $ 398.16 | $ 221.60 | $ 536.18 | $ 352.74 | $ 7,954.68 |
| ចំនាយក្នុងសហគមន៍ | $ 519.21 | $ 270.46 | $ 193.96 | $ 51.38 | $ 42.37 | $ 161.13 | $ 163.18 | $ 235.63 | $ 275.02 | $ 119.43 | $ 156.13 | $ 103.82 | $ 2,291.72 |
| **ថវិកាដែលនៅសល់** | **$ 2,318.75** | **$ 1,106.64** | **$ 906.94** | **$ (11.78)** | **$ 44.47** | **$ 3.67** | **$ 128.42** | **$ 311.57** | **$ 123.14** | **$ 102.17** | **$ 380.05** | **$ 248.92** | $ 5,662.96 |

- ឆ្នាំ២០២១

SARAY CBET - គម្រោងចំណូលចំនាយឆ្នាំ 2021( មករា-មិថុនា )

| សិប្បកម្មកំប្លោក | Jan | Feb | Mar | Apr | May | Jun | Total |
|---|---|---|---|---|---|---|---|
| ចំណូល | | | | | | | |
| ការលក់នៅលើផែ | $ 395.00 | $ 760.00 | $ - | $ 251.00 | $ - | $ - | **$ 1,406.00** |
| ការលក់តាមការបញ្ជាទិញ | $ 416.30 | $ 942.30 | $ 549.50 | $ 927.40 | $ 166.80 | $ 620.55 | **$ 3,622.85** |
| ការបង្រៀនភ្ញៀវទេសចរណ៍ | $ 395.00 | $ 32.50 | $ - | $ 251.00 | $ - | $ - | **$ 678.50** |
| ចំណូលពីភ្ញៀវទេសចរណ៍ដែលមកតាមរយៈអង្គការOsmose | | $ 32.50 | | | | | **$ 32.50** |
| ចំណូលពីភ្ញៀវទេសចរណ៍ដែលមកតាមរយៈGuide | $ 395.00 | $ 760.00 | $ - | $ 251.00 | | | **$ 1,406.00** |
| **ថវិកាសរុប** | **$ 1,601.30** | **$ 2,527.30** | **$ 549.50** | **$ 1,680.40** | **$ 166.80** | **$ 620.55** | $ 7,145.85 |
| ចំណាយ | | | | | | | |
| សំរាប់កម្លាំងពលកម្មស្រ្តី | $ 486.78 | $ 1,129.88 | $ 329.70 | $ 707.04 | $ 100.08 | $ 372.25 | **$ 3,125.73** |
| ថវិកាសំរាប់ប្រើប្រាស់ក្នុងសហគមន៍ | $ 324.52 | $ 604.92 | $ 219.80 | $ 417.36 | $ 66.72 | $ 248.30 | **$ 1,881.62** |
| ចំនាយក្នុងសហគមន៍ | $ 234.92 | $ 160.01 | $ 95.83 | $ 207.60 | $ 80.94 | $ 89.55 | **$ 868.85** |
| **ថវិកាដែលនៅសល់** | **$ 89.60** | **$ 444.91** | **$ 123.97** | **$ 209.76** | **$ (14.22)** | **$ 158.75** | $ 1,012.77 |

**សម្គាល់៖**

❖ **ប្រភពចំណូលរបស់សហគមន៍សិប្បកម្មកំប្លោកសារាយទន្លេៈ**

– ការលក់នៅលើផែ

– ការលក់តាមការបញ្ជាទិញ

– ការបង្រៀនភ្ញៀវទេសចរណ៍

– ចំណូលភ្ញៀវទេសចរណ៍តាមរយៈអង្គការOsmose

– ចំណូលភ្ញៀវទេសចរណ៍តាមរយៈGuide

❖ **ការចំណាយរបស់សហគមន៍សិប្បកម្មកំប្លោកសារាយទន្លេៈ**

_ ចំណាយទៅលើថ្លៃកម្លាំងពលកម្មរបស់សិប្បករ

_ ចំណាយសម្រាប់ទ្រទ្រង់ក្នុងសហគមន៍

# ជំពូកទី៣

## លទ្ធផលនៃការវិភាគសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ

# ជំពូកទី៣

# លទ្ធផលនៃការវិភាគសិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេ

## ៣.១. ស្ថានភាពទូទៅរបស់សិប្បករ

ដោយយោងតាមកិច្ចសម្ភាសន៍តាមរយៈទូរស័ព្ទជាមួយ នឹងសិប្បករបានឲ្យដឹងថាជីវភាពរស់នៅរបស់ពួកគាត់ប្រចាំថ្ងៃមានលក្ខណៈសាមញ្ញ និងងាយស្រួល។ មុខរបរប្រចាំថ្ងៃរបស់ពួកគាត់គឺ ការនេសាទ ធ្វើចម្ការដាំម្ទេស និងកែច្នៃប្រហុកទៅតាមរដូវកាល។ ក្រៅពីប្រកបមុខរបរទាំងអស់នេះហើយគ្រួសារមួយចំនួនបានងាកមកចូលរួមធ្វើការជាមួយសហគមន៍សារាយទន្លេ ដែលបុរសជាប្តីបានទទួលការងារជាអ្នកអុំទូកនាំភ្ញៀវទេសចរណ៍ជិះកំសាន្តក្នុងតំបន់ព្រែកទាល់។ ចំណែកឯប្រពន្ធជាស្ត្រីមេផ្ទះក៏បានមកចូលរួមជាមួយ និងសហគមន៍សារាយទន្លេខាងផ្នែកសិប្បកម្មកែច្នៃកំប្លោក។ ការងារទាំងនេះបានចូលរួមចំណែកទ្រទ្រង់ដល់ជីវភាពគ្រួសារពួកគាត់បានមួយចំណែកធំ។ ហើយសម្រាប់របរកែច្នៃកំប្លោកនេះបានធ្វើឲ្យពួកគាត់ទទួលបានប្រាក់ចំណូលបន្ថែមព្រមទាំងទទួលបានការហូបចុកគ្រប់គ្រាន់ក្នុងគ្រួសារ និងអាចមានលទ្ធភាពបញ្ជូនកូនៗឲ្យទៅសាលារៀនផងដែរ។ ប្រាក់ចំណូលរបស់ពួកគាត់ខុសគ្នាជាងពាក់កណ្តាល ប្រសិនបើធៀបជាមួយនឹងកាលដែលគាត់មិនទាន់មកចូលរួមប្រកបរបរកែច្នៃកំប្លោក។ ប៉ុន្តែបច្ចុប្បន្នដោយសារតែការវាយលុកពីជំងឺកូវីដ១៩បានធ្វើឲ្យប្រាក់ចំណូលរបស់សិប្បករក្នុងសហគមន៍បានបាត់បង់មួយភាគធំបណ្តាលមកពីការធ្លាក់ចុះនៃការកម្ម៉ង់ និងចំនួនភ្ញៀវទេសចរណ៍ដែលបានមកកំសាន្ត។ ក្នុងអំឡុងពេលដែលការកម្ម៉ង់មានការធ្លាក់ចុះសិប្បករមួយចំនួនកំពុងធ្វើចម្ការដាំម្ទេសខ្លះទៀតស៊ីឈ្នួលបេះផ្លែម្ទេស និងកាត់ក្បាលត្រីសម្រាប់កែច្នៃទៅជាប្រហុក។

### ៣.១.១. ឆ្នាំនៃការចាប់ផ្តើមធ្វើការក្នុងសហគមន៍

ដោយយោងទៅតាមទិន្នន័យខាងក្រោមបានបង្ហាញថា សិប្បករភាគច្រើនបានចាប់ផ្តើមចូលរួមធ្វើការជាមួយសហគមន៍ក្នុងឆ្នាំ២០១៨ដោយសារតែមានការកម្ម៉ង់ច្រើន ហើយក៏ជាឆ្នាំដែលសិប្បកម្មទទួលបានការចាប់អារម្មណ៍ខ្លាំងពីអតិជន និងភ្ញៀវទេសចរណ៍ដែលជាហេតុធ្វើឲ្យខាងសិប្បកម្មមានលទ្ធភាពជ្រើសរើសនូវសិប្បករបន្ថែម។ ដោយសារតែកត្តាទាំងអស់នេះបានផ្តល់ឱកាសដល់ប្រជាជនក្នុងតំបន់ទទួលបានការងារ និងទទួលបានប្រាក់ចំណូលបន្ថែម។

ខាងក្រោមជា តារាងទិន្នន័យដែលបង្ហាញពីចំនួនរបស់សិប្បករតាមឆ្នាំនីមួយៗ៖




ប្រភព: សហគមន៍សារាយទន្លេ

ក្នុងកំឡុងឆ្នាំ២០២១នេះ ចំនួនសិប្បករមានការធ្លាក់ចុះយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់ ដែលបណ្តាលមកពីការកម្ម៉ង់មានចំនួនតិចបំផុត និងលែងមានភ្ញៀវទេសចរណ៍មកកំសាន្តនៅតំបន់ព្រែកទាល់នេះបន្តទៀតដែលបណ្តាលមកពីបញ្ហាជំងឺឆ្លងកូវីដ១៩ ។

### ៣.១.២. គុណសម្បត្តិ និងគុណវិបត្តនៃការធ្វើការក្នុងសហគមន៍

#### ក. គុណសម្បត្តិ

- ទទួលបានប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារគ្រប់គ្រាន់
- ការហូបចុកគ្រប់គ្រាន់
- មានលទ្ធភាពក្នុងការបញ្ជូនកូនៗទៅសាលារៀន
- មានលទ្ធភាពសងប្រាក់កម្ចីពីឥណទាន
- ទទួលបានការបណ្តុះបណ្តាលផ្នែករចនាម៉ូតកំប្លោកពីគ្រូជំនាញមកពីបរទេស
- ទទួលបានបទពិសោធន៍ធ្វើការជាក្រុម
- ទទួលបានជំនាញថ្មី( ជំនាញកែច្នៃកំប្លោក )

#### ខ. គុណវិបត្ត

- ខ្វះខាតទីផ្សារ
- ពេលវេលាមិនគ្រប់គ្រាន់ក្នុងការតម្បាញ
- ជួបប្រទះនឹងបញ្ហាខ្វះខាតកំប្លោក

## ៣.២. បញ្ហាប្រឈម

### ៣.២.១. សហគមន៍

#### ក. បញ្ហាផ្លូវច្បាប់

ដោយយោងតាមសេចក្ដីណែនាំអន្តរក្រសួងស្ដីពីការអនុវត្តមុខងារផ្ដល់សេវាក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ បានលើកឡើងថាការគ្រប់គ្រង និងការចុះបញ្ជីសិប្បកម្ម សហគ្រាសធុនតូច ដែលគ្មានហានិភ័យ និងមានទុនវិនិយោគសមមូល៨០លានរៀលចុះក្រោម ការបង្កើត ឬការចុះបញ្ជី ការចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ការបន្ថែមមុខផលិតផលថ្មីការពង្រីកផលិតកម្ម ការប្ដូរទីតាំងសិប្បកម្ម ការប្ដូរម្ចាស់សិប្បកម្ម (ការផ្ទេរសិទ្ធិ) ការប្ដូរឈ្មោះសិប្បកម្ម និងការស្នើសុំលិខិតទុតិយតា ត្រូវតែធ្វើការស្នើសុំលិខិតអនុញ្ញាបង្កើត ឬចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូល ៨០ លានរៀលចុះក្រោម និងគ្មានហានិភ័យ និងការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្ម។ ចំពោះសិប្បកម្មសារាយទន្លេ គឺពុំទាន់បានចុះបញ្ជីនៅឡើយទេព្រោះការកែច្នៃផលិតផលធ្វើឡើងដោយដៃ ហើយម្យ៉ាងវិញទៀត ខាងសិប្បកម្មស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការ Omose(អូស្មូស)នៅឡើយ និងអ្វីដែលសំខាន់គឺចំណូលរបស់សហគមន៍នូវមានកំរិតដែលជាហេតុធ្វើឲ្យខាងសិប្បកម្មមិនទាន់អាចមានលទ្ធភាពសម្រាប់បង់ពន្ធបាន។

#### ខ. បញ្ហាជាក់ស្ដែង

បញ្ហាកន្លងមកដែលខាងសហគមន៍តែងតែជួបប្រទះ និងជាបញ្ហាចម្បងគឺការខ្វះខាតធនធានមនុស្សសម្រាប់ធ្វើទីផ្សារក្នុងការនាំចេញផលិតផល និងមិនសូវផ្ដោតសំខាន់ទៅលើការផ្សព្វផ្សាយដែលជាហេតុធ្វើឲ្យការលក់មិនសូវរីកចម្រើនខ្លាំង។ លើសពីនេះទៅទៀតដោយសារស្ថានភាពបច្ចុប្បន្នកំពុងមានភាពតានតឹងបណ្ដាលមកពីជំងឺឆ្លងកូវីដ១៩ ដែលធ្វើឲ្យសិប្បកម្មជួបប្រទះនូវការបាត់បង់ចំណូលស្ទើរតែទាំងស្រុង និងធ្វើឲ្យសិប្បករមួយចំនួនបានលាឈប់ទៅប្រកបរបរផ្សេងៗសម្រាប់ចិញ្ចឹមជីវិត។

### ៣.២.២. សិប្បករ

#### ក. បញ្ហាផ្លូវច្បាប់

ផ្នែកផ្លូវច្បាប់ចំពោះសិប្បករពុំទាន់ទទួលបានកិច្ចសន្យាការងារតាមផ្លូវច្បាប់នៅឡើយទេ។ ខាងសហគមន៍ក៏ពុំបានកំណត់លក្ខខណ្ឌ និងអត្ថប្រយោជន៍ដល់ពួកគាត់ឲ្យបានជាក់លាក់នោះទេ ដែលបញ្ជាក់ថាពួកគាត់ពុំមានថ្ងៃឈប់សម្រាក់ត្រឹមត្រូវ មិនទទួលបានរបបសោធនសន្តិសុខសង្គម និងគ្មានសំណងនៅពេលជួបគ្រោះថ្នាក់ក្នុងអំឡុងពេលធ្វើការនោះឡើយ។ ផលប៉ះពាល់ចំពោះសិប្បករនៅពេល ដែលគ្មានកិច្ចសន្យាការងារច្បាស់លាស់នោះសិប្បករអាចទទួលបានប្រាក់កម្រៃមិនទៀងទាត់ និងខាងសហគមន៍អាចបញ្ឈប់ពួកគាត់បានគ្រប់ពេលវេលាដោយមិនអាចតវ៉ាបានឡើយ។

### ខ. បញ្ហាជាក់ស្តែង

ជាការពិតណាស់ឥឡូវនេះ គ្រប់សិប្បករទាំងអស់កំពុងជួបប្រទះបញ្ហានូវការបាត់បង់ការងារ បាត់បង់ប្រាក់កម្រៃសម្រាប់ជីវភាពប្រចាំថ្ងៃ ដែលតម្រូវឲ្យសិប្បករមួយចំនួនធ្វើចំណាកស្រុកទៅរកការងារធ្វើនៅតំបន់ផ្សេងៗ ខ្លះទៀតត្រូវធ្វើការកម្ចីប្រាក់ពីខាងឥណទានដើម្បីមកដោះទាល់បញ្ហាជីវភាព។ ទន្ទឹមនឹងនេះពួកគាត់ក៏ត្រូវប្រឈមនឹងបញ្ហាសុខភាពដែលបណ្តាលមកពីការហូបចុកមិនគ្រប់គ្រាន់ អាហារគ្មានជីវជាតិ ហើយម្យ៉ាងទៀតកូនៗរបស់ពួកគាត់ត្រូវផ្អាកការសិក្សាផងដែរ។

### ៣.៣. ដំណោះស្រាយ

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើខាងអង្គការអូស្មូស និងសហគមន៍សារាយទន្លេក៏មានដំណោះស្រាយដោយផ្តែកទៅលើការខិតខំប្រឹងប្រែស្វែងរកទីផ្សារបន្ថែម និងរៀបចំផែនការយុទ្ធសាស្រ្តទីផ្សារឡើងវិញព្រមទាំងធ្វើការចុះបញ្ជីសិប្បកម្មឲ្យបានត្រឹមត្រូវស្របទៅតាមផ្លូវច្បាប់។ ជាងនេះទៅទៀតខាងសហគមន៍ក៏ព្យាយាមជួយជ្រោមជ្រែងដល់សិប្បករ ដែលមានជីវភាពលំបាកឲ្យមានភាពប្រសើរឡើងតាមរយៈការផ្តល់ការងារក្រៅពីការងារតម្បាញកំប្លោកដូចជា រៀបចំផ្ទះស្នាក់ជូនភ្ញៀវទេសចរណ៍ និងនាំភ្ញៀវទេសចរណ៍ដើរកំសាន្តជុំវិញតំបន់ព្រែកទាល់។ បច្ចុប្បន្ននេះខាងសហគមន៍កំពុងព្យាយាមសហការជាមួយអង្គការនានា ដែលជួយគាំទ្រទៅលើផ្នែកផលិតផលដែលកែច្នៃចេញពីរុក្ខជាតិលើទឹកដើម្បីនាំចេញទៅកាន់ប្រទេសអង់គ្លេស។ ប៉ុន្តែគម្រោងត្រូវបានផ្អាកដំណើរការបណ្តោះអាសន្នដោយសារតែការរាំងស្ទះពីជំងឺកូវីដ១៩ពួកគាត់ នឹងបន្តដំណើរការគម្រោងនេះនៅពេលដែលស្ថានភាពប្រសើរឡើងវិញ។

### ៣.៤. ទិសដៅអនាគត

តាមរយៈការលើកឡើងរបស់ប្រធានសហគមន៍**លោក ដុល វិចិត្រ**បានបញ្ជាក់ឲ្យដឹងថាសហគមន៍ក៏មានបំណងក្នុងការពង្រីកទីផ្សារបន្ថែមទាំងក្នុងស្រុក និងក្រៅស្រុកដើម្បីបង្កើនប្រាក់កម្រៃដល់សិប្បករ និងសមាជិកបុគ្គលិកទាំងអស់របស់សហគមន៍។ ហើយលោកក៏បានបន្តទៀតថាខាងសហគមន៍នឹងមានគម្រោងក្នុងការបង្កើនធនធានមនុស្សដែលមានជំនាញផ្នែកទីផ្សារសម្រាប់ជាជំនួយដល់ការអភិវឌ្ឍន៍ផ្នែកលក់ និងការផ្សព្វផ្សាយឲ្យកាន់តែមានប្រសិទ្ធិភាពខ្លាំងជាងមុន។ លើសពីនេះទៅទៀតលោកក៏បានបន្តថាអង្គការអូស្មូស (Omose) ក៏មានបំណងជម្រុញឲ្យសហគមន៍សារាយទន្លេផ្តាច់ចេញពីការគ្រប់គ្រងរបស់អង្គការ ពោលគឺខាងសហគមន៍អាចដំណើការបានដោយពុំចាំបាច់ពឹងផ្អែកទៅលើការជួយជ្រោមជ្រែងពីអង្គការទៀតឡើយ ដោយមានភាពឯករាជ្យដូចសហគមន៍ដ៏ទៃទៀត។ ជាចុងក្រោយលោកបានលើកឡើងថាខាងសហគមន៍នឹងព្យាយាមបង្កើតកិច្ចសន្យាការងារឲ្យបានច្បាស់លាស់ដើម្បីការពារផលប្រយោជន៍រួមទាំងខាងសិប្បកម្មនិងសិប្បករ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ ការគ្រប់គ្រងសហគមន៍អាជីវកម្មធុនតូច «សិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបងចាប់ផ្តើមពីឆ្នាំ២០១៦-២០២១» យើងអាចសន្និដ្ឋានបានថាកន្លងមកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាគឺពឹងផ្អែកទៅលើវិស័យកសិកម្មជាស្នូល។ យ៉ាងណាមិញបច្ចុប្បន្នប្រទេសកម្ពុជាបានឈានផុតពីប្រទេសពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្មមកពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសិប្បកម្មវិញដោយកំណើនក្នុងវិស័យនេះបានកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ បន្ថែមពីនេះទៅទៀតសហគ្រាសធុនតូច និងមធ្យមរបស់កម្ពុជាទាំងនេះបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចជាតិទាំងមូល។

តំបន់ព្រែកទាល់គឺជាតំបន់ដែលមានសក្តានុពលផ្នែកទេសចរណ៍ ដែលសម្បូរទៅដោយធនធានធម្មជាតិដែលទាក់ទាញភ្ញៀវទេសចរណ៍ឲ្យមកកំសាន្តជាហូរហែរ ដែលជាកត្តាមួយជួយដល់ជីវភាពប្រជាជនក្នុងតំបន់បានយ៉ាងល្អប្រសើរ។ ទន្ទឹមនឹងនេះប្រជាជនក្នុងតំបន់ព្រែកទាល់ក៏បានចូលរួមជាមួយសហគមន៍សារាយទន្លេដែលជ្រើសរើសយកជំនាញផ្នែកតម្បាញកំប្លោកឲ្យទៅជាវត្ថុប្រើប្រាស់ប្រចាំថ្ងៃដើម្បីជារបរបន្ថែម និងជាចំណូលសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ក្រោយពីបានចូលរួមជាមួយសហគមន៍មកប្រជាជនទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនដូចជា ទទួលបានការហូបចុកគ្រប់គ្រាន់ក្នុងគ្រួសារមានលទ្ធភាពក្នុងការដោះស្រាយបំណុល និងបញ្ជូនកូនៗទៅសាលារៀន។ ក្រៅពីអត្ថប្រយោជន៍ទាំងនេះសហគមន៍ក៏បានផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកតម្បាញកំប្លោកនិងការចេញម៉ូតកំប្លោកទុកជាចំណេះដឹង និងអាជីពបន្ថែម។ ក៏ប៉ុន្តែស្ថានភាពបច្ចុប្បន្នរបស់សិប្បកម្ម និងសិប្បករតឡូវនេះកំពុងតែប្រឈមនឹងការបាត់បង់ចំណូលយ៉ាងខ្លាំងដោយសារតែជំងឺរាលដាលកូវីដ១៩ ដែលបានធ្វើឲ្យសិប្បកម្មផ្អាកដំណើរការជាបណ្តោះអាសន្នដែលជាហេតុនាំឲ្យសិប្បករមួយចំនួនត្រូវធ្វើចំណាកស្រុកទៅទីកន្លែងផ្សេងៗដើម្បីស្វែងរកការងារចិញ្ចឹមជីវិត។

ជាចុងក្រោយសហគមន៍អាជីវកម្មធុនតូចពិតជាបានចូលរួមក្នុងការជម្រុញដល់សេដ្ឋកិច្ច និងកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជននៅក្នុងសហគមន៍ពិតប្រាកដមែន។

# អនុសាសន៍

# អនុសាសន៍

ដើម្បីចូលរួមជម្រុញដល់អាជីវកម្មសហគមន៍ធុនតូចឲ្យមានការអភិវឌ្ឍន៍និងរីកចម្រើនដោយមិនអាចខ្វះខាតបាន យើងខ្ញុំទាំងពីរសូមចូលរួមបញ្ចេញមតិយោបល់ក្នុងន័យស្ថាបនា កែលម្អចំណុចខ្វះខាតដូចខាងក្រោមតទៅ៖

- ចំពោះស្ថាប័នរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ

➢ បើកវគ្គបណ្តុះបណ្តាលដែលទាក់ទងនឹងបច្ចេកទេសក្នុងការកែច្នៃម៉ូតកំប្លោក

➢ បើកវគ្គបណ្តុះបណ្តាលទាក់ទងនឹងវិធីសាស្ត្រផ្នែកទីផ្សារ ដើម្បីឲ្យសិប្បករទទួលបានប្រាក់ចំណូល

➢ ជួយសម្រួលដល់ការរៀបចំឯកសារផ្លូវច្បាប់

➢ បង្កើនការផ្សព្វផ្សាយឲ្យបានច្រើនជាងនេះទៅទៀតទាក់ទងនឹងគុណភាពផលិតផលដែលកែច្នៃដោយដៃ

➢ ជម្រុញឲ្យអាជ្ញាធរ និងក្រសួងស្ថាប័នដែលពាក់ព័ន្ធចូលរួមក្នុងការការពារ និងអភិរក្សបឹងធម្មជាតិដែលជាកន្លែងលូតលាស់របស់រុក្ខជាតិលើទឹក(កំប្លោក) ព្រោះប្រសិនបើយើងគិតទៅដល់ពេល៥ឆ្នាំខាងមុខអាជីវកម្មកែច្នៃកំប្លោកនិងមានភាពរីកចម្រើនជាងនេះទៅទៀតដែលធ្វើឲ្យការផ្គត់ផ្គង់កំប្លោកនឹងអាចមានការខ្វះខាតមិនអាចបំពេញតម្រូវការទីផ្សារបាន

➢ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធគួរតែជួយជ្រោមជ្រែងផ្នែកផ្លូវច្បាប់ដល់សហគមន៍សិប្បកម្មដែលមានទីតាំងស្ថិតនៅតំបន់ដាច់ស្រយាល

➢ ជម្រុញឲ្យអាជ្ញាធរមូលដ្ឋានចូលរួមសំណេះសំណាលជាមួយសិប្បករ និងលើកទឹកចិត្តឲ្យពួកគាត់យកចិត្តទុកដាក់ធ្វើការ។

- ចំពោះសិប្បកម្ម

➢ ពង្រឹង និងពង្រីកបន្ថែមនូវផ្នែកទីផ្សារក្នុងស្រុក ព្រមទាំងការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ

➢ ផ្តល់នូវការលើកទឹកចិត្ត និងអត្ថប្រយោជន៍បន្ថែមទៅដល់សិប្បករ

➢ រៀបចំរចនាសម្ព័ន្ធ និងឯកសារក្នុងការគ្រប់គ្រងសហគមន៍សិប្បកម្មឲ្យបានច្បាស់លាស់ជាងនេះ

➢ រៀបចំជួសជុលកន្លែងលក់(ផែ)ឲ្យមានភាពទាក់ទាញ និងអនាម័យ

- ចំពោះសិប្បករ

➢ បង្កើនភាពច្នៃប្រឌិតដោយខ្លួនឯងឲ្យបានច្រើន

➢ គួរតែធ្វើកំណត់ត្រាចំណូល ចំណាយឲ្យបានច្បាស់លាស់

➢ គួរតែសិក្សាស្វែងយល់ពីការធ្វើយុទ្ធសាស្ត្រទីផ្សារដោយខ្លួនឯង

➢ គួរតែអភិវឌ្ឍន៍សមត្ថភាពក្នុងការតម្បាញឲ្យបានរហ័ស និងប្រសើរជាងមុន។

# ឯកសារយោង

# ឯកសារយោង


## ១. លិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម
- សេចក្តីណែនាំអន្តរក្រសួង ស្តីពី ការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០

## ២. ប្រភពសៀវភៅផ្សេងៗ

- សារណាបញ្ចប់ការសិក្សា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាផ្អែកលើសហគ្រាសខ្នាតតូចនិងមធ្យម ស្នាដៃនិពន្ធដោយ ឡេង ស្រីភ័ស និង ស៊ុកម៉ាន់ឌី ឆ្នាំ២០២០
- សារណាបញ្ចប់ការសិក្សា ការអភិវឌ្ឍន៍សហគមន៍ ស្នាដៃនិពន្ធដោយ មឿន ចាន់សុផាន់ម៉ៃ និងច្រឹង វ៉ាន់ឆ្លើម ឆ្នាំ២០២០
- អ្នកដឹកនាំល្អ និពន្ធដោយអូន សារ៉ាត់ ខែតុលា ឆ្នាំ២០១៦

## ៣. គេហទំព័រ

- ប្រកាសស្តីពីការណែនាំអនុវត្តអនុក្រឹតស្តីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព(http://freshnewsasia.com/index.php/en/localnews/148607-2020-02-17-07-55-28.html) ចូលអាននៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១
- អង្គការទិន្នន័យអំពីការអភិវឌ្ឍន៍(https://opendevelopmentcambodia.net/km/topics/small-and-medium-enterprises-sme/) ចូលអាននៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១
- ផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រនៃទីស្តីការគណៈរដ្ឋមន្ត្រី( http://ocm.gov.kh/ocmwinwin20/wp-content/uploads/2018/11/Gender-Book-of-OCM.pdf) ចូលអាននៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១
- https://www.researchgate.net/publication/266165571_The_Importance_of_SMEs_in_Developing_Economies ចូលអាននៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១
- https://openjicareport.jica.go.jp/pdf/12245049_01.pdf ចូលអាននៅថ្ងៃទី២០ មេសា ឆ្នាំ២០២១
- https://documents1.worldbank.org/curated/en/377261468014381044/pdf/603690NWP0KH0S10BOX358315B01PUBLIC1.pdf ចូលអាននៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១
- Kenskin, H. , Senturk, C. , Sungur, O. & Kiris, M.K., «សារៈសំខាន់នៃសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច», សន្និសីទអន្តរជាតិលើកទី ២ ស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០១០ ទំព័រទី ១៨៣-១៩២ ។ ចូលអាននៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១

- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)., «គម្រោងពង្រឹងយុទ្ធសាស្ត្រសហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០១៥ ទំព័រទី១។ ចូលអាននៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១
- ធនាគារពិភពលោក.,«ស្វែងយល់ពីតម្រូវការសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាសម្រាប់សេវាកម្ម និងផលិតផល ហិរញ្ញវត្ថុ (អង់គ្លេស)»ឆ្នាំ២០១០។ ចូលអាននៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២១
- សហគ្រាសខ្នាតតូចនិងមធ្យ( SME)«https://opendevelopmentcambodia.net/km/topics/small-and-medium-enterprises-sme/»ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១
- Japhta, Rubin; Vizcarra, Vanessa; Bui, Thuy Thu; Yogi, Nyoman; Mel, Sokim., «ស្វែងយល់ពីឱកាសសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលគ្រប់គ្រងដោយស្ត្រីនៅកម្ពុជា (អង់គ្លេស)» ឆ្នាំ ២០១៩ ទំព័រទី១២។ ចូលអាននៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១
- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) «គម្រោងពង្រឹងយុទ្ធសាស្ត្រសហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០១៥ ទំព័រទី១។ ចូលអាននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១
- រាជរដ្ឋាភិបាលកម្ពុជា «ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ ២០០៥។ ចូលអាននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១
- ក្រសួងកិច្ចការនារី., «ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី» របាយការណ៍សង្ខេប ឆ្នាំ២០១៤, ទំព័រទី៤-៧។ ចូលអាននៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១
- រាជរដ្ឋាភិបាលកម្ពុជា.,«គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥»ឆ្នាំ ២០១៥. ចូលអាននៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១
- Layhy, C., «ស្ថានភាពបច្ចុប្បន្នរបស់សហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា៖ បញ្ហាហិរញ្ញវត្ថុរបស់មីក្រូ សហគ្រាស សហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០១៩, ទំព័រទី៣។ ចូលអាននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១
- នាយកដ្ឋានសហគ្រាសខ្នាតតូច និងមធ្យម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម., «ស្ថិតិសហគ្រាសខ្នាតតូច និងមធ្យមនិងមីក្រូសហគ្រាស» ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧។ ចូលអាននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១
- ការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា ឆ្នាំ២០១៥
- រាជរដ្ឋាភិបាលកម្ពុជា., «ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ ២០០៥។ ចូលអាននៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១

– ការណែនាំអនុវត្តអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព ចូលអាននៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១

– អាស៊ាន., «ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា», មិនមានថ្ងៃបរិច្ឆេទ។ ចូលអាននៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១

– រាជរដ្ឋាភិបាលកម្ពុជា., «ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម» ឆ្នាំ២០០៥។ ចូលអាននៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

– សហគ្រាសខ្នាតតូចនិងមធ្យ (SME)«https://opendevelopmentcambodia.net/km/topics/small-and-medium-enterprises-sme/»ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១

– DFDL«បច្ចុប្បន្នភាពពន្ធនៅកម្ពុជា៖សេចក្តីប្រកាសស្តីពីការលើកទឹកចិត្តពន្ធសហគ្រាសធុនតូចនិងមធ្យម», ឆ្នាំ ២០១៨។ ចូលអាននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១

– ក្រុមហ៊ុន KPMG Cambodia Ltd., “ការណែនាំស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម” ឆ្នាំ ២០២០។ ចូលអាននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១

– Vireak, T., «ធនាគារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម បានបើកដំណើរការជាផ្លូវការហើយ» ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១។

– Vireak, T., «ធនាគារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម បានបើកដំណើរការជាផ្លូវការហើយ» ឆ្នាំ២០២០។ ចូលអាននៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១។

– នីតិវិធីគយ/នីតិវិធីពិសេសhttp://v1.customs.gov.kh ចូលអាននៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

– http://kh.cc-times.com/posts/904 ចូលអាននៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

# គម្រងសំណួរ

## ការគ្រប់គ្រងសហគមន៍អាជីវកម្មធុនតូច សិប្បកម្មកែច្នៃកំប្លោកខេត្តបាត់ដំបង

## ករណីសិក្សា៖ សិប្បកម្មកែច្នៃកំប្លោកសហគមន៍សារាយទន្លេខេត្តបាត់ដំបង

ឈ្មោះអ្នកសម្ភាសន៍ ១. សារឿន សំប៉ង

២. អោម សូនីតា

**គោលបំណងក្នុងការសំភាសន៍៖**

ជំរាបសួរលោកពូ អ្នកមីង សុខសប្បាយដែរឬទេ? នាងខ្ញុំមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយសហការជាមួយលោកគ្រូម្នាក់កំពុងធ្វើសារណាថ្នាក់បរិញ្ញាប័ត្រផ្នែករដ្ឋបាលសាធារណៈ។ នាងខ្ញុំ ចង់សិក្សាស្វែងយល់អំពីដំណើការការងារ និងភាពរីកចម្រើនរបស់លោកពូ អ្នកមីងក្នុងការធ្វើអាជីវកម្មមួយនេះ។ រាល់ព័ត៌មានរបស់អ្នកមីង យើងខ្ញុំនឹងយកទៅប្រើប្រាស់សម្រាប់តែការសិក្សាក្នុងការសរសេរសារណានេះតែប៉ុណ្ណោះ។ ដូច្នេះ សូមលោកពូ អ្នកមីង បង ជួយឆ្លើយនូវសំណួរមួយចំនួន ដូចខាងក្រោម ៖

❖ **<u>សំណួរសំរាប់ម្ចាស់អាជីវកម្ម៖</u>**

១. ឈ្មោះរបស់អាជីវកម្ម? តើអាជីកម្មរបស់អ្នកជាសាជីវកម្ម ឯកកម្មសិទ្ធិ ឬ សហកម្មសិទ្ធ?

២.តើអាជីវកម្មមួយនេះជាអាជីវកម្មបើកថ្មី ឬបន្តពីគ្រួសារ?

៣.បើកដំណើរការរយៈពេលប៉ុន្មានឆ្នាំមកហើយ?

៤.តើអ្នកបានចុះបញ្ជីក្នុងក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មនៅខេត្តដែរឬទេ?

៥.តើអ្នកស្វែងរកវិធីសាស្រ្តផលិតខ្លួនឯង ឬមានគ្រូបណ្តុះបណ្តាល?

៦.តើអ្នកទទួលបោះដុំដែរឬទេ?

៧.តើអាជីវកម្មនេះត្រូវចំណាយដើមទុនប៉ុន្មានពេលបើកប្រតិបត្តិការដំបូង?

៨.តើកំប្លោកអាចកែច្នៃទៅរបស់អ្វីខ្លះ?

៩.ការធ្វើកំប្លោកផលិតដោយដៃទាំងស្រុង ឬក៏មានម៉ាស៊ីនជាជំនួយ?

១០.ចូររៀបរាប់ពីវិធីនៃការកែច្នៃកំប្លោកឲ្យទៅជាផលិតសម្រេច? ចំហុយរយៈពេលប៉ុន្មាន?

១១.ហេតុអ្វីបានជាលោកពូ អ្នកមីង បង ជ្រើសរើសកំប្លោកមកធ្វើជាកាបូប?

១២.ក្នុងមួយខែតើធ្វើបានកាបូបប៉ុន្មាន?

១៣.កាបូបមានគុណភាពយ៉ាងណាដែរឬទេ?

១៤.ទុកបានរយៈពេលយូរប៉ុនណា?

១៥.តើកាបូបមួយមានតម្លៃប៉ុន្មានខ្លះ?

១៦.តើអតិថិជនបែបណាខ្លះជាគោលដៅ?

១៧.តើផលិតផលរបស់អ្នកមានអតិថិជនបរទេសដែរឬទេ?

១៨.ប្រសិនបើមានតើមានប្រទេសណាខ្លះដែលធ្លាប់នាំចេញ?

១៩.តើមានចំនួនប៉ុន្មាន?

២០.ហើយទទួលបានចំណូលជាមធ្យមក្នុងមួយ១ខែប៉ុន្មាន? ១ឆ្នាំប៉ុន្មាន?

២១.នរណាជាអ្នកប្រឹក្សាផ្តល់យោបល់ក្នុងការនាំចេញ?

២២.នរណាជាអ្នកជួយក្នុងការដឹកជញ្ជូនទំនិញ?

២៣.តើអាជីវកម្មមួយនេះបានចូលរួមចំណែកដល់សហគមន៍អ្វីខ្លះ?

២៤.តើអ្នកមានផែនការទីផ្សារយ៉ាងដែរ? ឬក៏ការតាំងពិពណ៌?

២៥.មានការផ្សព្វផ្សាយពាណិជ្ជកម្មដែរឬទេ?

២៦.តើអ្នកមានវិធីសាស្រ្តបែបណាខ្លះទើបមានគេស្គាល់មុខរបររបស់អ្នក?

២៧.បង្ហាញពីវិធីសាស្រ្តប្រកួតប្រជែងនៅក្នុងទីផ្សារ

២៨.តើផលិតផលរបស់អ្នកមានលក់តាមប្រព័ន្ធបណ្តាញសង្គមដែរឬទេ? ប្រសិនបើមានតើទទួលបានការបញ្ជាទិញច្រើនដែរឬទេ?ប្រសិនបើគ្មានតើអ្នកមានគោលបំណងសាកល្បងដែរឬទេ?

២៩.តើអ្នកធ្លាប់ជួបបញ្ហាប្រឈមអ្វីខ្លះមុនកូវីដ?

៣០.តើអ្នកធ្លាប់ទទួលបានការជួយជ្រោមជ្រែងពីសំណាក់រដ្ឋាភិបាល ឬក្រសួងស្ថាប័នណាដែរឬទេ? ប្រសិនបើធ្លាប់តើជ្រោមជ្រែងយ៉ាងដូចម្តេច?

៣១.តើអ្នកទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យមប៉ុន្មានភាគរយ?

៣២.តើអ្នកចំណាយទៅលើអ្វីខ្លះក្នុងមួយខែ? (ស្នើសុំតារាងចំណូលប្រសិនបើអាច)

៣៣.តើអាជីវកម្មបានជួបប្រទះបញ្ហាអ្វីខ្លះក្នុងអំឡុងពេលកូវីដ?

៣៤.តើអ្នកមានកម្រោងបែបណាដើម្បីទទួលបានជោគជ័យនៅរយៈពេល៥ឆ្នាំខាងមុខទៀត?

៣៥.តើសិប្បកម្មរបស់អ្នកមានសមាជិកប៉ុន្មានអ្នក? ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

៣៦.តើអាជីវកម្មរបស់អ្នកមានចុះបញ្ជីនៅក្នុងក្រសួងការងារដែរឬទេ?

៣៧. តើអាជីវកម្មរបស់អ្នកមានរចនាសម្ព័ន្ធច្បាស់លាស់ហើយឬនៅ?

៣៨.តើមានប្រធានក្រុមដែរឬទេ? ប្រសិនបើមានតើប្រធានក្រុមមានតួនាទីអ្វីខ្លះ?

៣៩.តើសមាជិកនីមួយៗបានធ្វើការចុះកិច្ចសន្យាការងារដែរឬទេ?

៤០.តើសិប្បកម្មរបស់លោកពូ អ្នកមីង បង មានសរសេរលក្ខន្តិកៈច្បាស់លាស់ដែរឬទេ? ដូចជាកំណត់ពេលវេលាធ្វើការ និង ថ្ងៃធ្វើការជាដើម?

៤១.សមាជិកទាំងអស់មានទទួលបានប្រាក់ខែដែរឬទេ? ប្រសិនបើទទួលបានស្មើគ្នាដែរឬទេ? ហើយប្រសិនបើមិនស្មើខ្ពស់ជាងគេប៉ុន្មាន? ទាបជាងគេប៉ុន្មាន?

៤២. បើគ្មានប្រាក់ខែទេ តើពួកគាត់ទទួលបានចំណូលតាមរបៀបណាខ្លះ?

៤៣.ប្រសិនបើសមាជិកមានគ្រោះថ្នាក់ក្នុងម៉ោងធ្វើការ តើអ្នកមានសំណងដែរឬទេ?

៤៤. ជាចុងក្រោយ តើអ្នកមានជាសំណូមពរទៅកាន់រដ្ឋាភិបាល ឬអាជ្ញាធរដែនដី ដែរទេ? បើមាន អ្វីខ្លះ?

៤៥. ជាចុងក្រោយ តើអ្នកមានជាសំណូមពរទៅកាន់សមាជិករបស់អ្នក ដែរទេ? បើមាន អ្វីខ្លះ?

❖ <u>**សំណួរសម្រាប់សមាជិកៈ**</u>

១. តើអ្នកមកធ្វើការនៅទីនេះរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំហើយ?

២. តើអ្នកមានតួនាទីជាអ្វីនៅក្នុងកន្លែងសិប្បកម្មនេះ?

៣. តើអ្នកធ្វើការងារអ្វីខ្លះនៅទីនេះ?

៤. តើដំណើការការងារមានផលលំបាកអ្វីខ្លះ

៥. តើចំណុចខ្លាំង ឬគុណសម្បត្តិរបស់អ្នកនៅក្នុងកន្លែងសិប្បកម្មនេះមានអ្វីខ្លះ?

៦. តើអ្នកពេញចិត្តធ្វើការនៅទីនេះដែរឬទេ?

៦. តើចំណុចខ្វះខាតរបស់សិប្បកម្មនេះមានអ្វីខ្លះ?

៧. តើអ្នកទទួលបានការរៀនសូត្រអ្វីខ្លះពីកន្លែងសិប្បកម្មនេះ?

៨.តើអ្នកទទួលបានការបណ្តុះបណ្តាលជំនាញក្រៅពីនេះដែរឬទេ?

៩.តើអ្នកទទួលបានប្រាក់ខែ និងអត្ថប្រយោជន៍អ្វីខ្លះនៅពេលធ្វើការនៅទីនេះ?

១០. តើចំណូលរបស់អ្នកកើនឡើង នៅដដែល ឬថយចុះ បើប្រៀបធៀបនៅពេលមុនអ្នកមកធ្វើការនៅទីនេះ និងនៅពេលអ្នកធ្វើការនៅទីនេះ? ហេតុអ្វី?

១១. តើចំណូលរបស់អ្នកកើនឡើង នៅដដែល ឬថយចុះ បើប្រៀបធៀបនៅមុនពេលកើតជំងឺកូវីដ និងកំឡុងពេលកើតជំងឺកូវីដ? ហេតុអ្វី?

១២.តើម្ចាស់អាជីវកម្មបានយកចិត្តទុកដាក់ដល់អ្នកដែរឬទេ?

១៣.តើអ្នកយល់ឃើញចំពោះអាជីវកម្មនេះយ៉ាងដូចម្តេចដែរ?

១៤.តើមានមនុស្សប៉ុន្មាននាក់ដែលរស់នៅក្នុងគ្រួសារពឹងផ្អែកលើចំណូលរបស់អ្នក?

១៥. ចាប់តាំងពីមកធ្វើការនៅទីនេះមក តើការហូបចុករបស់អ្នកនិងសមាជិកក្នុងគ្រួសារបានគ្រប់គ្រាន់ដែរឬទេ?

១៦. ចាប់តាំងពីមកធ្វើការនៅទីនេះមក តើអ្នកមានបានសន្សំជាប្រាក់បានខ្លះឬទេ? បានប៉ុន្មានរៀល ឬដុល្លារ?

១៧. ចាប់តាំងពីមកធ្វើការនៅទីនេះមក តើអ្នកមានបានទិញសម្ភារៈសំខាន់ៗចូលផ្ទះខ្លះដែរឬទេ? អ្វីខ្លះ?

១៨.ប្រសិនបើមានលទ្ធភាពតើអ្នកចង់ប្រកបអាជីវកម្មមួយនេះដោយខ្លួនឯងដែរឬទេ? ហេតុអ្វី?

១៩. ជាចុងក្រោយ តើអ្នកមានជាសំណូមពរទៅកាន់ម្ចាស់សិប្បកម្ម ឬសមាជិកផ្សេងៗដែរទេ? បើមាន អ្វីខ្លះ?

**ជាចុងក្រោយ ខ្ញុំសូមអរគុណច្រើនចំពោះការចូលរួមក្នុងការឆ្លើយតបរបស់លោកពូ អ្នកមីង បង។ សូមជូនពរលោកពូ អ្នកមីង បងឱ្យមានសុខភាពល្អ និងជោគជ័យនៅក្នុងការប្រកបមុខរបរផ្សេងៗ។ សូមអរគុណ**!